ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# របាយការណ៍សង្ខេប



## បូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា

## ឆ្នាំសិក្សា២០១២ - ២០១៣ និងទិសដៅ

## ឆ្នាំសិក្សា២០១៣ - ២០១៤

ថ្ងៃទី១៩ - ២០ - ២១ ខែមីនា ឆ្នាំ២០១៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# របាយការណ៍សង្ខេប

## បូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា

## ឆ្នាំសិក្សា២០១២-២០១៣ និងទិសដៅឆ្នាំសិក្សា២០១៣-២០១៤

ថ្ងៃទី ១៩-២០-២១ ខែមីនា ឆ្នាំ២០១៤

# របាយការណ៍សង្ខេប
# បូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០១២-២០១៣

ក្នុងឆ្នាំសិក្សាកន្លងមកនេះ ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តកម្មវិធីនៃផែនការយុទ្ធសាស្រ្តវិស័យអប់រំ ២០០៩-២០១៣ ឆ្លើយតបទៅនឹងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលនីតិកាលទី៤ នៃរដ្ឋសភា ដែលបានដាក់ចេញឱ្យអនុវត្ត តាមរយៈផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ និងកំណែទម្រង់តាមការដ្ឋានសំខាន់ៗរបស់រាជរដ្ឋាភិបាល។

សមិទ្ធផលសំខាន់ៗរបស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងឆ្នាំសិក្សាកន្លងមក រួមមាន៖

## ១. លទ្ធផលរួមវិស័យអប់រំ យុវជន និងកីឡា

### ១.១ ការវិភាគវឌ្ឍនភាពនៃការអនុវត្តសកម្មភាពគោលនយោបាយក្នុងឆ្នាំ ២០១៣

ក្រសួងបានគ្រោងអនុវត្តសកម្មភាពគោលនយោបាយ ១០១។ សកម្មភាពគោលនយោបាយឆ្នាំ២០១២ មាន ៧៦ បានបញ្ចប់ ១៨ ស្មើនឹង ២៣,៦៨ ភាគរយ ៤២ កំពុងអនុវត្ត ស្មើនឹង ៥៥,២៦ ភាគរយ និង ១៦ មិនទាន់បានអនុវត្ត ស្មើនឹង ២១,០៥ ភាគរយ (រូបទី១)។ សកម្មភាពគោលនយោបាយឆ្នាំ២០១៣ មាន ២៥ បានបញ្ចប់ ៨ ស្មើនឹង ៣២ ភាគរយ សកម្មភាពគោលនយោបាយ ៩ ស្មើនឹង ៣៦ ភាគរយ បានអនុវត្តតែពុំទាន់ចប់សព្វគ្រប់ និងសកម្មភាពគោលនយោបាយ ៨ ផ្សេងទៀត ស្មើនឹង ៣២ ភាគរយ ពុំទាន់បានចាប់ផ្តើមអនុវត្តនៅឡើយ (រូបទី២)។

ជារួម សកម្មភាពគោលនយោបាយ ២៦ ស្មើនឹង ២៥,៧៤ ភាគរយ ត្រូវបានបញ្ចប់ ៥១ ស្មើនឹង ៥០,៥០ ភាគរយ កំពុងអនុវត្ត និង ២៤ ស្មើនឹង ២៣,៧៦ ភាគរយ មិនទាន់បានអនុវត្ត។

សកម្មភាពគោលនយោបាយដែលបានអនុវត្តចប់សព្វគ្រប់មាន សេចក្តីណែនាំស្តីពីការអនុវត្តការពន្លឿនការសិក្សាសម្រាប់ក្រុមគោលដៅពិសេស គោលនយោបាយអប់រំបច្ចេកទេសសម្រាប់សាលាមធ្យមសិក្សា សេចក្តីណែនាំស្តីពីការអនុវត្តការងារតម្រង់ទិសវិជ្ជាជីវៈ សេចក្តីណែនាំស្តីពីការវាយតម្លៃភាពជាដៃគូអប់រំនៅក្នុងការងារអប់រំក្រៅប្រព័ន្ធផ្អែកលើប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ សេចក្តីណែនាំស្តីពីការបង្កើតសមាគមកីឡានៅក្នុងគ្រឹះស្ថានបឋមនិងមធ្យមសិក្សា លិខិតបទដ្ឋានក្នុងការបង្កើតនិងគ្រប់គ្រងបណ្ណាល័យ លិខិតបទដ្ឋានដើម្បីបង្កើតកម្មវិធីវេជ្ជសាស្រ្តកីឡា កំណែទម្រង់ប្រព័ន្ធនៃការប្រកួតកីឡាគ្រប់ប្រភេទនិងគ្រប់កម្រិត សេចក្តីណែនាំស្តីពីការកសាងផែនការយុទ្ធសាស្រ្តវិស័យអប់រំសម្រាប់ដំណាក់កាលឆ្នាំ២០១៤-២០១៨ ការអនុវត្តផែនការសកម្មភាពស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងអប់រំ យុវជន និងកីឡា សេចក្តីណែនាំស្តីពីការអនុវត្តច្រកចេញចូលតែមួយ សេចក្តីណែនាំស្តីពីបែបបទការគ្រប់គ្រងរដ្ឋបាលនិងការទុកដាក់ឯកសារ ផែនការការពារគ្រោះមហន្តរាយនានា កម្មវិធីអធិការកិច្ចបានធ្វើបច្ចុប្បន្នកម្ម រៀបចំបញ្ជីវិភាគមុខងារវិស័យអប់រំ គោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ គោលនយោបាយស្តីពីគ្រូបង្រៀន។ល។

សកម្មភាពគោលនយោបាយដែលកំពុងអនុវត្តបន្តមាន ការរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយជាតិស្តីពីការគាំពារនិងអភិវឌ្ឍកុមារតូច លិខិតបទដ្ឋាននិងលក្ខណៈវិនិច្ឆ័យសម្រាប់ពង្រីកវិទ្យាល័យឱ្យទៅជាវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសអប់រំវិជ្ជាជីវៈ ចក្ខុវិស័យអភិវឌ្ឍឧត្តមសិក្សាឆ្នាំ២០៣០ កម្មវិធីបណ្តុះបណ្តាលគ្រូអប់រំកាយនិងកីឡាកម្រិតមូលដ្ឋាន ឯកសារស្តីពីអត្តសញ្ញាណក្បាច់គុនបុរាណខ្មែរ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា កសាងក្របខណ្ឌអភិវឌ្ឍកម្មវិធីសិក្សានៅឧត្តមសិក្សា ការគ្រប់គ្រងផ្អែកលើលទ្ធផលដូចជាការវាយតម្លៃការបំពេញការងាររបស់បុគ្គលិក សេចក្តីណែនាំស្តីពីការផ្សព្វផ្សាយលទ្ធផលសិក្សារបស់សិស្សសំដៅជំរុញការសិក្សានិងស្វ័យសិក្សារបស់សិស្ស ក្របខណ្ឌធានាគុណភាពអប់រំ គោលការណ៍ណែនាំអនុវត្តគោលនយោបាយស្តីពីសុខភាពសិក្សានៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ប្រកាសអន្តរក្រសួងស្តីពីការពិនិត្យសុខភាពដល់បុគ្គលិកអប់រំនិងអ្នកសិក្សា រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចតាមកម្រិតថ្នាក់រដ្ឋបាលស្របតាមការងារវិមជ្ឈការនិងវិសហមជ្ឈការវិស័យអប់រំ ផែនការមេសម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធអប់រំរយៈពេលមធ្យម លិខិតបទដ្ឋានស្តីពីតួនាទីនិងភារកិច្ច ការងារគ្រប់គ្រង ការងារតម្រង់ទិសវិជ្ជាជីវៈ គោលការណ៍ក្នុងការតែងតាំងមន្ត្រីគ្រប់គ្រងដោយផ្តល់អាទិភាពដល់ស្ត្រី គោលនយោបាយស្តីពីការអភិវឌ្ឍកម្មវិធីសិក្សាចំណេះទូទៅ ការពិនិត្យឡើងវិញនូវមុខងារវិស័យអប់រំ គោលនយោបាយស្តីពីអាហារូបករណ៍ ឧបត្ថម្ភធន និងឥណទានសិក្សា។ល។

សកម្មភាពគោលនយោបាយដែលមិនទាន់ចាប់ផ្តើមអនុវត្តមាន ផែនការបណ្តុះបណ្តាលធនធានមនុស្សថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់និងបណ្ឌិត យុទ្ធសាស្ត្រស្តីពីតម្រូវការនិងការផ្គត់ផ្គង់គ្រូបង្រៀន សេចក្តីណែនាំស្តីពីការផ្សព្វផ្សាយលទ្ធផលតេស្តស្តង់ដាររបស់សិស្សថ្នាក់ទី៣ ទី៦ និងទី៨ ស្តង់ដារជាតិដើម្បីធានាគុណភាពអប់រំ ប្រព័ន្ធព័ត៌មានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការរៀបចំឱ្យមានសាកលវិទ្យាល័យពេញលេញចំនួន ២ ។ល។

រូបទី១: វឌ្ឍនភាពនៃការអនុវត្តសកម្មភាពគោលនយោបាយគ្រោងក្នុងឆ្នាំ២០១២ (បន្តអនុវត្តក្នុងឆ្នាំ២០១៣)



រូបទី២ : វឌ្ឍនភាពនៃការអនុវត្តសកម្មភាពគោលនយោបាយក្នុងឆ្នាំ២០១៣(អនុវត្តក្នុងឆ្នាំ២០១៣)




បើប្រៀបធៀបទៅនឹងឆ្នាំ២០១២ ភាគរយសកម្មភាពគោលនយោបាយបានអនុវត្តចប់សព្វគ្រប់ថយចុះ ៨,១៥ ភាគរយ សកម្មភាពកំពុងអនុវត្តកើន ៥,០៥ ភាគរយ សកម្មភាពមិនទាន់បានអនុវត្តកើន ៣,១ ភាគរយ។ ប្រការនេះ ទាមទារឱ្យមានការពិចារណាឡើងវិញ អំពីវិសាលភាពការងារ និងសមត្ថភាពអនុវត្ត។

## ១.២ ការវិភាគវឌ្ឍនភាពនៃការសម្រេចចំណុចដៅសូចនាករបំពេញការងារ

### គោលនយោបាយទី១ : ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌

លទ្ធផលជាក់ស្តែងនៃសូចនាករបំពេញការងារ បានបង្ហាញពីវឌ្ឍនភាពពាក់ព័ន្ធនឹងការចូលរៀននៅកម្មវិធីអប់រំកុមារតូច បឋមសិក្សា ឧត្តមសិក្សា និងអត្រាអក្ខរកម្មយុវជន។ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាមិនទាន់ឆ្លើយតបទៅនឹងចំណុចដៅ។

ភាគរយកុមារអាយុ ៥ឆ្នាំបានចូលរៀនកើនឡើង ៣,៩៣ ភាគរយ អត្រាពិតនៃការសិក្សានៅបឋមសិក្សាសាធារណៈមានការថយចុះ ១,៤ ភាគរយ នៅពេលដែលអត្រាពិតនៃការសិក្សានៅសាលាបឋមសិក្សាឯកជនមាន ២,៦ ភាគរយ។ អត្រាអក្ខរកម្មយុវជន(អាយុ១៥-២៤ឆ្នាំ) បានកើន ០,៦ ភាគរយ។ ចំណុចនេះបញ្ជាក់ពីការខិតខំប្រឹងប្រែងរបស់មន្ត្រីអប់រំ អាជ្ញាធរដែនដី សហគមន៍ និងការចូលរួមពីវិស័យឯកជន។

| លរ | សូចនាករ | ជាក់ស្តែង | | ចំណុចដៅ | | |
|---|---|---|---|---|---|---|
| | | ២០១៣-២០១៤ | | ២០១៣-២០១៤ | | |
| | | សរុប | ស្រី | សរុប | ស្រី | |
| ១ | ភាគរយកុមារអាយុ៥ ឆ្នាំក្នុងការអប់រំកុមារតូចនៅគ្រប់រូបភាព | ៥៩,៩៣, % | ៤៨,៤៩% | ៦០% | ៦០% | ↑ |
| ២ | អត្រាពិតចូលរៀនថ្មី [១] | ៩៨,១% | ៩៨,២% | ១០០% | ១០០% | → |
| ៣ | អត្រាពិតនៃការសិក្សានៅបឋមសិក្សា [២] | ៩៨,២% | ៩៨,៥% | ៩៨,០% | ៩៨,០% | ↑ |
| ៤ | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ [៣] | ៥៥,៣% | ៥៦,២% | | | |
| ៥ | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ [៤] | ២៦,០% | ២៥,៧% | | | |
| ៦ | ចំនួននិស្សិតនៅគ្រឹះស្ថានឧត្តមសិក្សាទាំងសាធារណៈ និងឯកជន[៥] | ២៥៣ ៧៦៤ | ១០១ ៨១០ | ២០៦ ២០៣ | ៩៦ ៤២៣ | ↑ |
| ៧ | អត្រាអក្ខរកម្មយុវជន( អាយុ ១៥-២៤ឆ្នាំ) [៦] | ៩២,១% | ៩១,៣% | ៩២,០% | | ↑ |

↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ មិនសម្រេចបានតាមចំណុចដៅ

១. អត្រាពិតចូលរៀនថ្មីរាប់បញ្ចូលទាំងផ្នែកឯកជន (២,៨ ភាគរយ ស្រី ២,៩ ភាគរយ)

២. អត្រាពិតនៃការសិក្សានៅបឋមសិក្សារាប់បញ្ចូលទាំងផ្នែកឯកជន (២,៦ ភាគរយ ស្រី ២,៧ ភាគរយ)

៣. អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិរាប់បញ្ចូលទាំងផ្នែកឯកជន (១,៨ ភាគរយ ស្រី ១,៧ ភាគរយ)

៤. អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិរាប់បញ្ចូលទាំងផ្នែកឯកជន (១,១ ភាគរយ ស្រី ១,១ ភាគរយ)

៥. តួលេខនេះ រាប់បញ្ចូលនិស្សិតថ្នាក់បរិញ្ញាបត្ររង

៦. តួលេខរបស់វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការៈ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចនៅកម្ពុជាឆ្នាំ២០១២

## គោលនយោបាយទី២ : លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃសេវាអប់រំ

លទ្ធផលជាក់ស្តែងនៃសូចនាករបំពេញការងារ បានបង្ហាញពីវឌ្ឍនភាពវិជ្ជមានពាក់ព័ន្ធនឹងការកាត់បន្ថយអត្រាត្រួតថ្នាក់នៅគ្រប់ភូមិសិក្សា ការកាត់បន្ថយចំនួនសាលារៀនមិនគ្រប់កម្រិត និងផលធៀបសិស្ស-ថ្នាក់នៅបឋមសិក្សា។ ការកាត់បន្ថយអត្រាបោះបង់ការសិក្សា អត្រាបញ្ចប់ការសិក្សា ការប្រមូលកុមារក្នុងកម្មវិធីចូលរៀនឡើងវិញមិនទាន់ឆ្លើយតបនឹងចំណុចដៅ។ ការធ្វើតេស្តថ្នាក់ជាតិថ្នាក់ទី៦ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាបាននឹងកំពុងអនុវត្ត។

អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សានៅតែខ្ពស់ក្នុងរង្វង់ ២០ ភាគរយ មិនទាន់ឆ្លើយតបទៅនឹងចំណុចដៅ ដោយសារសិស្សមានអាយុច្រើនប្រមាណ ៣១ ភាគរយ និងអត្រាត្រួតថ្នាក់នៅបឋមសិក្សាមានកម្រិតខ្ពស់ ៤,៨ ភាគរយ។

អត្រាត្រួតថ្នាក់មានការថយចុះជាលំដាប់ពី ៥,៣ ភាគរយ (ស្រី ៤,៥ ភាគរយ) នៅឆ្នាំសិក្សា២០១១-២០១២ មក ៤,៨ ភាគរយ (ស្រី ៤,១ ភាគរយ) នៅឆ្នាំសិក្សា២០១២-២០១៣។ ប្រការនេះ បញ្ជាក់ឱ្យឃើញពីប្រសិទ្ធភាពផ្ទៃក្នុងនៃប្រព័ន្ធអប់រំ។

| ល.រ | សូចនាករ | ជាក់ស្តែង | | ចំណុចដៅ | | |
|---|---|---|---|---|---|---|
| | | ២០១៣-២០១៤ | | ២០១៣-២០១៤ | | |
| | | សរុប | ស្រី | សរុប | ស្រី | |
| ៨ | ផលធៀបសិស្ស-ថ្នាក់នៅបឋមសិក្សា | ៣៨,៩ | | ៤៥,០ | | ↑ |
| ៩ | ផលធៀបគ្រូ-ថ្នាក់ នៅបឋមសិក្សា | ០,៩ | | ១,០ | | ↑ |
| ១០ | អត្រាត្រួតថ្នាក់ (ឆ្នាំសិក្សា២០១២-២០១៣) | | | | | |
| | បឋមសិក្សា | ៤,៨% | ៤,១% | ៥,០% | ៥,០% | ↑ |
| | មធ្យមសិក្សាបឋមភូមិ | ១,៤% | ០,៩% | ១,០% | ១,០% | ↑ |
| | មធ្យមសិក្សាទុតិយភូមិ | ១,៦% | ១,០% | ២,០% | ១,០% | ↑ |
| ១១ | អត្រាបោះបង់ការសិក្សា (២០១២-២០១៣) | | | | | |
| | បឋមសិក្សា | ១០,៥% | ៨,៣% | ៥,០% | ៥,០% | ↓ |
| | មធ្យមសិក្សាបឋមភូមិ | ២១,២% | ២០,៩% | ១២,០% | ១៤,០% | ↓ |
| | មធ្យមសិក្សាទុតិយភូមិ | ១៤,០% | ១២,២% | ៨,០% | ៧,០% | ↓ |
| ១២ | អត្រាបញ្ចប់ការសិក្សា | | | | | |
| | បឋមសិក្សា | ៨៨,៩៤% | ៩០,១៩% | ១០០% | ១០០% | ↓ |
| | មធ្យមសិក្សាបឋមភូមិ | ៣៩,៥៥% | ៤០,០២% | ៥៤,០% | ៥៣,០% | ↓ |
| | មធ្យមសិក្សាទុតិយភូមិ | ២២,៧៤% | ២២,១០% | ៣១,០% | ២៩,០% | ↓ |
| ១៣ | ចំនួនសិស្សចូលរៀនឡើងវិញនៅថ្នាក់ទី៣ ដល់ទី៦ | ១៧,៣៩៧ | | ២២,០០០ | | ↓ |
| ១៤ | ចំនួនសាលារៀនបឋមសិក្សាមិនគ្រប់កម្រិត | ៨១៦ | | | | ↑ |
| ១៥ | ផលធៀបសៀវភៅ-សិស្សនៅថ្នាក់ទី១-៣ (១សម្រាប់មាន ៣ក្បាល) | ២,៧ | | ៣,០ | | ↑ |
| | ផលធៀបសៀវភៅ-សិស្សនៅថ្នាក់ទី៤-៦ (១សម្រាប់មាន ៤ក្បាល) | ៣,៩៧ | | ៤,០ | | ↑ |
| ១៦ | ស្តង់ដារជាតិវាយតម្លៃលទ្ធផលសិក្សារបស់សិស្សលើមុខវិជ្ជាភាសាខ្មែរ | | | | | |
| | ថ្នាក់ទី ៣ | បញ្ចប់ | | បញ្ចប់ | | → |
| | ថ្នាក់ទី ៦ | កំពុងអនុវត្ត | | បញ្ចប់ | | → |
| ១៧ | ស្តង់ដារជាតិវាយតម្លៃលទ្ធផលសិក្សារបស់សិស្សលើមុខវិជ្ជាគណិតវិទ្យា | | | | | |
| | ថ្នាក់ទី ៣ | បញ្ចប់ | | បញ្ចប់ | | → |
| | ថ្នាក់ទី ៦ | កំពុងអនុវត្ត | | បញ្ចប់ | | → |
| ១៨ | ភាគរយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈនិងឯកជនគោរព តាមលក្ខខណ្ឌនៃការបង្កើត | ៦២,០ % | | ៩៥% | | ↓ |

↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ មិនសម្រេចបានតាមចំណុចដៅ

**សម្គាល់:** ស្ថិតិសាលាបឋមសិក្សា និងមធ្យមសិក្សាសាធារណៈស្ថិតក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា

### គោលនយោបាយទី៣: អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ

លទ្ធផលជាក់ស្តែងនៃសូចនាករបំពេញការងារ បានបង្ហាញពីវឌ្ឍនភាពពាក់ព័ន្ធនឹងការកាត់បន្ថយការប្រើប្រាស់ទីប្រឹក្សាបច្ចេកទេសជាតិនិងអន្តរជាតិ និងបង្កើនភាគរយបុគ្គលិកអប់រំជាស្ត្រី។ ការបែងចែកថវិកាចរន្តសម្រាប់វិស័យអប់រំ អង្គភាពនិងសាលារៀនត្រូវធ្វើសវនកម្មមិនទាន់ឆ្លើយតបទៅនឹងចំណុចដៅ។

ថវិកាចរន្តសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា ធៀបនឹងថវិកាជាតិ មានការកើនឡើងនៅ ឆ្នាំ ២០១៤ (១៦,២៣ ភាគរយ)។ ភាគរយបុគ្គលិកបង្រៀន ថ្នាក់ដឹកនាំនិងគ្រប់គ្រងជាស្ត្រី មានការកើនឡើងជាលំដាប់ ដោយសារការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំក្រសួង និងក្រុមការងារយេនឌ័រក្នុងការលើកកម្ពស់ភាពអង់អាចរបស់ស្ត្រីក្នុងវិស័យអប់រំ។

| លរ | សូចនាករ | ជាក់ស្តែង ២០១៣ | ចំណុចដៅ ២០១៣ | |
|---|---|---|---|---|
| ១៩ | ថវិកាចរន្តសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា (រដ្ឋ និងថវិកាផ្សេងៗទៀត) ធៀបនឹងថវិកាជាតិ * | ១៥,៥២% | ២១,0% | ↓ |
| ២០ | ភាគរយចំណាយថវិកាកម្មវិធីជាក់ស្តែងធៀបនឹងថវិកាកម្មវិធីសរុប | ៩៣,២០% | ៩៥,0% | → |
| ២១ | ភាគរយអង្គភាពអនុវត្តថវិកាដែលត្រូវធ្វើសវនកម្មផ្ទៃក្នុងក្នុង១ឆ្នាំ | ៤១,៧៣% | ៧០,៦៦% | ↓ |
| ២២ | ភាគរយសាលារៀននិងគ្រឹះស្ថានសិក្សាដែលត្រូវធ្វើសវនកម្មផ្ទៃក្នុងក្នុង១ឆ្នាំ | ៤,៧% | ៨,៤% | ↓ |
| ២៣ | ជំនួយការបច្ចេកទេស(នាក់-ខែ) ជាតិ និងអន្តរជាតិ | ១៣១ | ៣៣៩ | ↑ |
| ២៤ | ភាគរយបុគ្គលិកអប់រំជាស្ត្រី | ៤១,៤៨% | | ↑ |
| | បុគ្គលិកបង្រៀន | ៤៧,៥% | | ↑ |
| | មន្ត្រីគ្រប់គ្រងថ្នាក់មធ្យម(ប្រធាន អនុប្រធាននាយកដ្ឋាន និងមន្ទីរអេយករាជធានី ខេត្ត) | ១០,៥% | | ↑ |
| | ថ្នាក់ដឹកនាំ (ចាប់ពីអគ្គនាយករងឡើងទៅ) | ១០,៥% | | ↑ |

↑សម្រេចបានតាមចំណុចដៅ →អាចទទួលយកបាន ↓មិនសម្រេចបានតាមចំណុចដៅ

* ថវិកាចរន្តសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា

## ១.៣ ការវិភាគវឌ្ឍនភាពនៃការសម្រេចសូចនាករស្នូល

លទ្ធផលជាក់ស្តែងនៃសូចនាករស្នូលបានបង្ហាញពីវឌ្ឍនភាពពាក់ព័ន្ធនឹង ភាគរយកុមារអាយុ ៥ឆ្នាំក្នុងការអប់រំកុមារតូចគ្រប់រូបភាព និងចំនួនសាលារៀនបឋមសិក្សាគ្រប់កម្រិតដែលមានអត្រាត្រួតថ្នាក់តិចជាង ១០ ភាគរយ និងការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំថ្នាក់ក្រោមជាតិ។ ចំណែកលទ្ធផលជាក់ស្តែងនៃសូចនាករដកសាច់ប្រាក់ទាន់ពេលនៃថវិកាកម្មវិធីស្ថិតនៅក្រោមចំណុចដៅ និងការធ្វើតេស្តថ្នាក់ជាតិថ្នាក់ទី៦ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាបាននឹងកំពុងអនុវត្ត។

ចំនួនសាលាបឋមសិក្សាគ្រប់កម្រិតមានអត្រាត្រួតថ្នាក់តិចជាង ១០ ភាគរយ មានការកើនឡើងស្តង់ដារជាតិវាយតម្លៃលទ្ធផលសិក្សារបស់សិស្សកំពុងអនុវត្ត ដើម្បីរៀបចំឧបករណ៍ស្តង់ដារជាតិមួយ។ ភាគរយនៃការដកសាច់ប្រាក់ទាន់ពេលវេលានៃថវិកាកម្មវិធីមានការកើនឡើងពី ៨៧,៥៩ ភាគរយ នៅឆ្នាំ ២០១២ ដល់ ៩៤,៥៦ ភាគរយ នៅឆ្នាំ២០១៣។ ប្រការនេះបញ្ជាក់ពីប្រសិទ្ធភាពនៃកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងវិស័យអប់រំ។

| សូចនាករស្នូល | ស្ថានភាពបច្ចុប្បន្ន ឆ្នាំ ២០១៣ | ចំណុចដៅ ឆ្នាំ ២០១៣ | |
|---|---|---|---|
| **គោលនយោបាយទី១ :ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌** | | | |
| - ភាគរយកុមារអាយុ៥ ឆ្នាំក្នុងការអប់រំកុមារតូចនៅគ្រប់រូបភាព | ៥៩,៩៣% | ៦០% | ↑ |
| - ចំនួនស្រុកដែលបានសម្រេចអត្រាបញ្ចប់បឋមសិក្សាយ៉ាងតិច ៨០ភាគរយ | ១៣០ | ១៤០ | → |
| **គោលនយោបាយទី ២ : លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ** | | | |
| - ចំនួនសាលារៀនបឋមសិក្សាគ្រប់កម្រិតមានអត្រាត្រួតថ្នាក់តិចជាង១០ភាគរយ | ៥ ៣៣៦ លើ ៦ ១៧៧ | ៤ ៧៥០ លើ ៦ ១៧៧ | ↑ |
| - ស្តង់ដារជាតិវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស | | | |
| ថ្នាក់ទី៣ | បញ្ចប់ | បញ្ចប់ | → |
| ថ្នាក់ទី៦ | កំពុងអនុវត្ត | បញ្ចប់ | ↓ |
| ថ្នាក់ទី៨ | មិនទាន់អនុវត្ត | បញ្ចប់ | ↓ |
| **គោលនយោបាយទី ៣ : អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ** | | | |
| - ការដកសាច់ប្រាក់ទាន់ពេលនៃថវិកាកម្មវិធី* | ៩៤,៥៦% | ១០០% | → |
| - ផែនការប្រតិបត្តិប្រចាំឆ្នាំថ្នាក់ក្រោមជាតិត្រូវបានអនុវត្ត | ២៤ | ២៤ | ↑ |

↑សម្រេចបានតាមចំណុចដៅ →អាចទទួលយកបាន ↓មិនសម្រេចបានតាមចំណុចដៅ

*ការដកសាច់ប្រាក់ទាន់ពេលនៃថវិកាកម្មវិធីឆ្នាំ២០១៣

<u>សម្គាល់:</u> ស្ថិតិសាលាបឋមសិក្សា និងមធ្យមសិក្សាសាធារណៈស្ថិតក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា

## ១.៤ វឌ្ឍនភាពនៃប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ

- បានរៀបចំកម្មវិធីវិនិយោគសាធារណៈឆ្នាំ២០១៤-២០១៦ មាន ២៩គម្រោង
- បានទទួលហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់វិស័យអប់រំឆ្នាំ២០១៣ ជាង ៨០លានដុល្លារ
- បានរៀបចំអង្គវិបស្សនាអប់រំរួមគ្នារវាងក្រសួង និងដៃគូអភិវឌ្ឍ
- បានរៀបចំសូចនាករពិនិត្យតាមដានរួមគ្នាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍។

## ១.៥ វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- បានពង្រឹងការអនុវត្តគោលនយោបាយចំណូល និងចំណាយ
- បានពង្រឹងការរៀបចំថវិកាកម្មវិធី និងត្រៀមលក្ខណៈអនុវត្តថវិកាកម្មវិធីពេញលេញនាឆ្នាំ២០១៥
- បានពង្រឹងការអនុវត្តចំណាត់ថ្នាក់ថវិកា និងគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ
- បានផ្សព្វផ្សាយនីតិវិធីនៃការអនុវត្តថវិកាកម្មវិធី
- បានពង្រឹង និងពង្រីកការប្រើប្រាស់ប្រព័ន្ធធនាគារ
- បានរៀបចំប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ។

## ១.៦ វឌ្ឍនភាពនៃការអនុវត្តវិមជ្ឈការ និងវិសហមជ្ឈការវិស័យអប់រំ

- បានរៀបចំបញ្ជីវិភាគមុខងារវិស័យអប់រំ
- បានពង្រឹងសមត្ថភាពបុគ្គលិកអប់រំដែលត្រូវទៅបម្រើការងារនៅក្រុង ស្រុក ខណ្ឌគោលដៅនៃការិយាល័យច្រកចេញចូលតែមួយ
- បានពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងអប់រំស្តីពីអភិបាលកិច្ចល្អសម្រាប់ពង្រឹងការផ្តល់សេវាសាធារណៈវិស័យអប់រំ
- បានដាក់ឱ្យដំណើរការច្រកចេញចូលតែមួយនៅក្នុងក្រសួងអប់រំ យុវជន និងកីឡា
- បានរៀបចំសេចក្តីព្រាងគោលនយោបាយស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការវិស័យអប់រំ
- បានពិនិត្យឡើងវិញនូវមុខងារវិស័យអប់រំ ដើម្បីកំណត់មុខងារសម្រាប់ផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

# ២- លទ្ធផលនៃការដោះស្រាយសំណូមពរៀនសូត្រ ការលើកកម្ពស់គុណភាព និងការពង្រឹងការខារគ្រប់គ្រង

## ២.១ ការខារអប់រំកុមារតូច

មត្តេយ្យសិក្សាមាន ៥ ៨០៧ កើន ៣៣៧ សាលា/កន្លែង ក្នុងនោះមត្តេយ្យសិក្សារដ្ឋមាន ៣ ១៨៤ កើន ៣៧១ សាលា/កន្លែង (មត្តេយ្យសិក្សាដាច់ដោយឡែក ២១១ កើន ៩) មត្តេយ្យសិក្សាឯកជនមាន ៤០៣ កើន ៥៥ សាលា និងមត្តេយ្យសិក្សាសហគមន៍មាន ២ ២២០ កន្លែង ថយ ៨៩ កន្លែង។ ថ្នាក់រៀនមាន ៨ ៩១១ កើន ៨២១ ក្នុងនោះថ្នាក់មត្តេយ្យសិក្សារដ្ឋមាន ៤ ៩២៩ កើន ៦៨១ មត្តេយ្យសិក្សាឯកជនមាន ១ ៥៥០ កើន ១២៧ និងមត្តេយ្យសិក្សាសហគមន៍មាន ២ ៤៣២ កើន ១៣។

កុមារអាយុពី ០ ទៅក្រោម ៦ឆ្នាំ បានទទួលសេវាអប់រំមាន ៣២៨ ៧២៣ នាក់ ស្មើនឹង ១៧,៥៩ ភាគរយ នៃក្រុមអាយុ ស្រី ៤៩,៥០ ភាគរយ។ កុមារអាយុពី ០ ទៅក្រោម ៣ឆ្នាំមាន ៣៧ ៦០៦ នាក់ ស្មើនឹង ៣,៧៨ ភាគរយនៃក្រុមអាយុ ស្រី ៥០,៣៣ ភាគរយ។ កុមារអាយុ៣ និង ៤ឆ្នាំមាន ១២០ ៥៩៦ នាក់ ស្មើនឹង ២០,៥០ ភាគរយ នៃក្រុមអាយុ ស្រី ៥០,៦៧ ភាគរយ។ កុមារអាយុ ៥ឆ្នាំ មាន ១៧០ ៥២១ នាក់ ស្មើនឹង ៥៩,៩៣ ភាគរយ នៃក្រុមអាយុ ស្រី ៤៨,៤៩ ភាគរយ (ចំណុចដៅ ESP ៦០ ភាគរយ ) ។

ការអប់រំកុមារតូចតាមផ្ទះ និងក្រុមខ្ទង់ផ្ទះមាន ១៨១ ក្រុង ស្រុក ខណ្ឌ។ អ្នកចូលរួមកម្មវិធីអប់រំកុមារតូចតាមផ្ទះមាន ៧៨ ៤៨៨ នាក់ ក្នុងនោះម្ដាយបង្គោលមាន ២ ៦០០ នាក់ និងកុមារមាន ៧៩ ២២៤ នាក់ ស្រី ៥១,៥២ ភាគរយ។

បុគ្គលិកអប់រំមត្តេយ្យសិក្សាសរុប ១០ ១៥៨ នាក់ ស្រី ៩១,២៨ ភាគរយ ក្នុងនោះមត្តេយ្យសិក្សារដ្ឋមាន ៤ ៧១៧ នាក់ ស្រី ៩៥,៣៣ ភាគរយ មត្តេយ្យសិក្សាឯកជនមាន ២ ៩១៨ នាក់ ស្រី ៧៩,១៩ ភាគរយ និងមត្តេយ្យសិក្សាសហគមន៍មាន ២ ៥២៣ នាក់ ស្រី ៩៧,៧០ ភាគរយ។

- រៀបចំព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច និងអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច
- រៀបចំសេចក្តីណែនាំស្តីពីដំណើរការគ្រឹះស្ថានបឋមសិក្សា និងមត្តេយ្យសិក្សាសាធារណៈ
- បញ្ចប់សេចក្ដីព្រាងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផលសម្រាប់អនុវិស័យអប់រំកុមារតូច
- រៀបចំឯកសារស្តង់ដារអប្បបរមា មណ្ឌល សាលា ថ្នាក់ ផ្នែកមត្តេយ្យសិក្សាសហគមន៍ និងកម្មវិធីអប់រំកុមារតូចតាមផ្ទះ
- រៀបចំសេចក្ដីសម្រេចទទួលស្គាល់គ្រូឧទ្ទេសថ្នាក់ក្រោមជាតិ
- រៀបចំគោលការណ៍ណែនាំស្តីពីសាលាមត្តេយ្យសិក្សាធនធាន
- រៀបចំគោលការណ៍ណែនាំស្តីពីការអប់រំមត្តេយ្យសិក្សាសហគមន៍ និងការអប់រំកុមារតូចតាមផ្ទះ និងក្រុមខ្ទង់ផ្ទះ
- បញ្ចប់ការរៀបចំតារាងម៉ាទ្រិចផលសម្រេចសម្រាប់អនុវិស័យអប់រំកុមារតូច។

### បញ្ហាប្រឈម

- ខ្វះគ្រូមត្តេយ្យសិក្សារដ្ឋ និងសម្ភារបរិក្ខា
- សមត្ថភាពគ្រូមត្តេយ្យសិក្សា និងគ្រូបឋមសិក្សាដែលបង្រៀននៅមត្តេយ្យសិក្សានៅមានកម្រិត
- កម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សាមិនទាន់ឆ្លើយតបទៅនឹងស្តង់ដារសិក្សារបស់កុមារ
- រចនាសម្ព័ន្ធកម្មវិធីអប់រំកុមារតូចតាមផ្ទះនៅកម្រិតភូមិ មានការផ្លាស់ប្តូរញឹកញាប់
- ការគាំទ្រនិងការលើកទឹកចិត្តសម្រាប់សេវាមត្តេយ្យសិក្សាសហគមន៍មិនទាន់មានការចូលរួមពីគ្រប់ផ្នែកពាក់ព័ន្ធបានពេញលេញ។

### បទពិសោធ

- មានគោលនយោបាយជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច
- ការប្រមូលកុមារអាយុ៣ ទៅក្រោម ៦ឆ្នាំ មានការកើនឡើងដោយសារមានការចូលរួមពីសំណាក់ប្រជាជន អាជ្ញាធរដែនដី
- មានគោលការណ៍ណែនាំអនុវត្តស្តីពីកម្មវិធីអប់រំកុមារតូចតាមផ្ទះ និងគោលការណ៍ណែនាំអនុវត្តស្តីពីសេវាមត្តេយ្យសិក្សាសហគមន៍
- មានគោលការណ៍ណែនាំដំណើរការកម្មវិធីអប់រំមាតាបិតា
- មានការយកចិត្តទុកដាក់ពីសំណាក់នាយកសាលាបឋមសិក្សាមួយចំនួនធំចំពោះថ្នាក់មត្តេយ្យសិក្សា
- មានការយល់ដឹងពីសារៈសំខាន់នៃមត្តេយ្យសិក្សាពីសំណាក់មាតាបិតា ដោយបានយកចិត្តទុកដាក់ដល់ការរៀនសូត្ររបស់កុមារ
- មានកិច្ចសហការល្អរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងដៃគូអភិវឌ្ឍ ដើម្បីអភិវឌ្ឍការងារអប់រំកុមារតូច។

## ២.២ ការងារបឋមសិក្សា

សាលាបឋមសិក្សាមាន ៦ ៩៩៣ កើន ៨៣។ កម្រងសាលារៀនមាន ១ ២១២ កើន ២៤។ សាលាកុមារមេត្រីមាន ៥ ០៦៨ (កម្រិតមធ្យមនិងអភិវឌ្ឍ) ស្មើនឹង ៧២,៤៧ ភាគរយ កើន ៨៨ ស្មើនឹង ១,៧៧ ភាគរយ។ សាលាបឋមសិក្សាមិនគ្រប់កម្រិតមាន ៨១៦ ស្មើនឹង ១១,៦៧ ភាគរយ នៃចំនួនសាលាបឋមសិក្សាសរុប (ថយ ១៣៦)។ សិស្សមាន ២ ០៧៣ ៨១១ នាក់ ស្រី ៤៧,៩៨ ភាគរយ ថយ ៩៩ ៥៧៣ នាក់ ស្មើនឹង ៤,៦ ភាគរយ។ សាលាបឋមសិក្សាឯកជនមាន ២៤៣ សិស្សមាន ៥៤ ៨២២ នាក់ ស្រី ៥០,២ ភាគរយ។

អត្រាពិតចូលរៀនថ្មី ៩៨,១ ភាគរយ (ចំណុចដៅ ESP ១០០ ភាគរយ) ស្រី ៩៨,២ ភាគរយ ក្នុងនោះអត្រាពិតចូលរៀនថ្មីរបស់សាលាឯកជន ២,៨ ភាគរយ ស្រី ២,៩ ភាគរយ។ អត្រាពិតនៃការសិក្សា ៩៨,២ ភាគរយ (ចំណុចដៅ ESP ៩៨ ភាគរយ) ស្រី ៩៨,៥ ភាគរយ ក្នុងនោះអត្រាពិតនៃការសិក្សារបស់សាលាឯកជន ២,៦ ភាគរយ ស្រី ២.៧ ភាគរយ។

អត្រាឡើងថ្នាក់ ៨៥,៧ ភាគរយ ស្រី ៨៧,៦ ភាគរយ។ អត្រាត្រួតថ្នាក់ ៤,៨ ភាគរយ ស្រី ៤,១ ភាគរយ (ចំណុចដៅ ESP ៥ ភាគរយ)។ អត្រាបោះបង់ការសិក្សា ១០,៥ ភាគរយ ស្រី ៨,៣ ភាគរយ (ចំណុចដៅ ESP ៥ ភាគរយ)។ អត្រាឆ្លងភូមិសិក្សា ៧៦,៨ ភាគរយ ស្រី ៨១,៤ ភាគរយ។ អត្រាបញ្ចប់ការសិក្សា ៨៨,៩៤ ភាគរយ ស្រី ៩០,១៩ ភាគរយ (ចំណុចដៅ ESP ១០០ ភាគរយ)។

ចំនួនសាលារៀនបឋមសិក្សាគ្រប់កម្រិត ដែលមានអត្រាត្រួតថ្នាក់តិចជាង ១០ ភាគរយ មាន ៥ ៣៣៦ សាលា លើ ៦ ១៧៧ សាលា (ចំណុចដៅ ៤ ៧៥០ សាលា)។ ចំនួនក្រុង ស្រុក ខណ្ឌ ដែលបានសម្រេចអត្រាបញ្ចប់បឋមសិក្សាយ៉ាងតិច ៨០ ភាគរយ មាន ១៣០ លើ ១៩៤ (ចំណុចដៅ ១៥០ ស្រុក)។

### បញ្ហាប្រឈម

- កង្វះគ្រូឯកទេសផ្នែកភាសាបរទេសនៅបឋមសិក្សា
- កង្វះគ្រូនិងបណ្ណារក្សនៅតំបន់ដាច់ស្រយាលជួបការលំបាក
- ការអនុវត្តកាលវិភាគ និងម៉ោងសិក្សាមិនទាន់ឆ្លើយតបនឹងស្តង់ដារ (៨០០ ទៅ ១០០០ ម៉ោង)
- ការធ្វើតេស្តចុងឆ្នាំសិក្សា និងដើមឆ្នាំសិក្សាមិនបានអនុវត្ត ១,៨៣ ភាគរយ
- ចំណាកស្រុកបានជះឥទ្ធិពលដល់ការបោះបង់ការសិក្សា
- សិស្ស និងគ្រូមួយចំនួននៅតំបន់លិចទឹកមិនទាន់ចេះហែលទឹក (បំណិនជីវិត)។

### បទពិសោធ

- ភាពជាម្ចាស់នៃការអនុវត្តកម្មវិធីស្បៀងតាមសាលារៀនដោយក្រសួងផ្ទាល់នៅខេត្តកំពត និងក្រចេះ
- ការធានាតម្លាភាព និងភាពទាន់ពេលក្នុងការផ្ទេរសាច់ប្រាក់នៃកម្មវិធីអាហារូបករណ៍ តាមរយៈធនាគារចល័ត
- ការអនុវត្តកម្មវិធីអំណាននិងសំណេរថ្នាក់ទី១ ទី២ ទី៣ និងការបង្កើតបណ្ណាល័យនៅតាមសាលារៀនបានជួយសិស្សឱ្យមានមូលដ្ឋានរឹងមាំលើការអាន និងសរសេរ
- កម្មវិធីអប់រំបញ្ចូលគ្នាបានផ្តល់ឱកាសដល់ក្រុមបាត់បង់ឱកាស (កុមារពិការ ជនជាតិដើមភាគតិច យេនឌ័រ កុមាររងគ្រោះដោយជំងឺអេដស៍ មេរោគអេដស៍ កុមារលើសអាយុ ពលកម្មកុមារ...) ប្រកបដោយសមធម៌ និងគុណភាព
- ការរៀបចំថ្នាក់រៀនបណ្តោះអាសន្ននៅតាមផ្ទះ ឬទីទួលសុវត្ថិភាពក្នុងពេលមានទឹកជំនន់ បានជួយឱ្យសិស្សរៀនចប់កម្មវិធីសិក្សា
- សៀវភៅទំនាក់ទំនងមាតាបិតាបានជួយបង្កើនទំនាក់ទំនងជិតស្និទ្ធរវាងសាលារៀននិងគ្រួសារ
- ការបំពាក់សង្ហារិម និងផ្តល់សៀវភៅអានដល់បណ្ណាល័យជួយលើកទឹកចិត្តសិស្ស និងគ្រូឱ្យស្រឡាញ់ និងមានទម្លាប់អាន។

## ២.៣ ការងារមធ្យមសិក្សា

គ្រឹះស្ថានមធ្យមសិក្សាមាន ១ ៦៨៨ ក្នុងនោះអនុវិទ្យាល័យ ១ ២៤៤ និងវិទ្យាល័យ ៤៤៤ ចែកជាវិទ្យាល័យពីថ្នាក់ទី៧ ដល់១២ មាន៤១៥ និងវិទ្យាល័យពីថ្នាក់ទី១០ ដល់ទី១២ មាន២៩។ អនុវិទ្យាល័យកើន

៣០ និងវិទ្យាល័យកើន ១១ ក្នុងចំណោមវិទ្យាល័យទាំង ៤៤៤ មានវិទ្យាល័យធនធាន ២៩។ សាលាកុមារមេត្រីមធ្យមសិក្សាបឋមភូមិមាន ៩២៣ ស្មើនឹង ៥៥,៦៣ ភាគរយ នៃសាលារៀនដែលមានកម្រិតមធ្យមសិក្សាបឋមភូមិសរុប ១ ៦៥៩ ក្នុងនោះសាលាកុមារមេត្រីបែបម្ចាស់ការមាន ៧២៣ ផ្ទេរពីសាលារៀនមានប្រសិទ្ធភាពរបស់គម្រោងទ្រទ្រង់វិស័យអប់រំកម្ពុជា ១០០ និងគាំទ្រដោយគម្រោងកែលម្អអប់រំកំរិតមូលដ្ឋាននៅកម្ពុជា ១០០។ អនុវិទ្យាល័យឯកជនមាន ៣៥ សិស្សមាន ១ ៨២៨ នាក់ ស្រី ៥៦,៥ ភាគរយ។ វិទ្យាល័យឯកជនមាន ៨៧ សិស្សមាន ២៧ ៦៤៤ នាក់ ស្រី ៤៦,៩ ភាគរយ។

សិស្សមធ្យមសិក្សាបឋមភូមិមាន ៥៣៨ ៦២៦ នាក់ ស្រី ៤៩,៧១ ភាគរយ។ អត្រារួមនៃការសិក្សា ៥៥,៣ ភាគរយ ស្រី ៥៦,២ ភាគរយ ក្នុងនោះអត្រារួមនៃការសិក្សាសាលាឯកជន ១,៨ ភាគរយ ស្រី ១,៧ ភាគរយ។

មធ្យមសិក្សាបឋមភូមិមាន អត្រាឡើងថ្នាក់ ៧៧,៤ភាគរយ (ចំណុចដៅ ESP ៨៥,៦ ភាគរយ) ស្រី ៧៨,៣ ភាគរយ (ចំណុចដៅ ESP ៨៣,៨ ភាគរយ)។ អត្រាត្រួតថ្នាក់ ១,៤ភាគរយ (ចំណុចដៅ ESP ១,៤ ភាគរយ) ស្រី ០,៩ ភាគរយ (ចំណុចដៅ ESP ១,២ ភាគរយ)។ អត្រាបោះបង់ការសិក្សា ២១,២ ភាគរយ (ចំណុចដៅ ESP ១៣ ភាគរយ) ស្រី ២០,៩ ភាគរយ (ចំណុចដៅ ESP ១៥ ភាគរយ)។

សិស្សមធ្យមសិក្សាទុតិយភូមិមាន ២៦៦ ២៩៣ នាក់ ស្រី ៤៧,៧០ ភាគរយ។ អត្រារួមនៃការសិក្សា ២៦,០ ភាគរយ ស្រី ២៥,៧ ភាគរយ ក្នុងនោះអត្រារួមនៃការសិក្សារបស់សាលាឯកជន ១,១ ភាគរយ ស្រី ១,១ ភាគរយ។

មធ្យមសិក្សាទុតិយភូមិមាន អត្រាឡើងថ្នាក់ ៨៤,៤ ភាគរយ (ចំណុចដៅ ESP ៨៨,៨ ភាគរយ) ស្រី ៨៦,៨ ភាគរយ (ចំណុចដៅ ESP ៩០,៨ ភាគរយ)។ អត្រាត្រួតថ្នាក់ ១,៦ ភាគរយ (ចំណុចដៅ ESP ២,២ ភាគរយ) ស្រី ១,០ ភាគរយ (ចំណុចដៅ ESP ១,២ ភាគរយ)។ អត្រាបោះបង់ការសិក្សា ១៤ ភាគរយ (ចំណុចដៅ ESP ៩,០ ភាគរយ) ស្រី ១២,២ ភាគរយ (ចំណុចដៅ ESP ៨,០ ភាគរយ)។

លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិមាន ៩៣,០១ ភាគរយ ស្រី ៩៥,៥៨ ភាគរយ។ លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ៨៦,៧៧ ភាគរយ ស្រី ៩២,៧៧ ភាគរយ ក្នុងនោះនិទ្ទេស A ៨៦ នាក់ ថយ ១៨,១ ភាគរយ និទ្ទេស B ៥ ០៥២ នាក់ កើន ៤០,១ ភាគរយ និទ្ទេស C ២២ ៨៥០ នាក់ កើន ២៨,៤ ភាគរយ និងនិទ្ទេស D ៣៦ ៥១០ នាក់ ថយ ២,៧ ភាគរយ និងនិទ្ទេស E ២៦ ៨៧២ នាក់ ថយ ២៧,៥ ភាគរយ។

លទ្ធផលប្រកួតប្រជែងអ្នកវិទ្យាសាស្ត្រអូឡាំព្យាដអន្តរជាតិវ័យក្មេងអាយុក្រោម ១៥ឆ្នាំបេក្ខជនកម្ពុជាជាប់ជ័យលាភីមេដាយសំរិទ្ធ ៣ នាក់។ សិស្សអាហារូបករណ៍មធ្យមសិក្សាបឋមភូមិមាន ៥៦ ៥៣៤ នាក់ ស្រី ៥៩,៧៥ ភាគរយ គាំទ្រដោយថវិកាកម្មវិធី ៣ ០១២ នាក់ ស្រី ៧៩,១៥ ភាគរយ និងគាំទ្រដោយគម្រោងនានារបស់ដៃគូអភិវឌ្ឍ។ សិស្សអាហារូបករណ៍មធ្យមសិក្សាទុតិយភូមិមាន ២ ៥០០ នាក់ ស្រី ៦០ ភាគរយ គាំទ្រដោយគម្រោងលើកកម្ពស់គុណភាពអប់រំ។

អនុវិទ្យាល័យ ៨៤,៨ ភាគរយ មានបង្គន់អនាម័យ និង ៤៨,៦ ភាគរយ មានទឹកស្អាត។ វិទ្យាល័យ ៩៨,០ ភាគរយ មានបង្គន់អនាម័យ និង ៦២,៦ ភាគរយ មានទឹកស្អាត។

### បញ្ហាប្រឈម

- កង្វះគ្រូមធ្យមសិក្សាទុតិយភូមិ និងមធ្យមសិក្សាបឋមភូមិតាមមុខវិជ្ជាឯកទេសមួយចំនួននៅតាមវិទ្យាល័យ និងអនុវិទ្យាល័យដែលបង្កើតថ្មី ពិសេសតំបន់ជួបការលំបាក
- ថវិកាអាហារូបករណ៍នៅមានកម្រិត មិនអាចធានាអត្រាគង់វង្សរបស់សិស្សអាហារូបករណ៍
- កង្វះផ្ទះគ្រូស្នាក់នៅ និងអន្តេវាសិកដ្ឋានសិស្សតំបន់ជួបការលំបាក។

### បទពិសោធ

- បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងដំណើរការសាលាមធ្យមសិក្សាធនធាន តាមរយៈការប្រជុំបូកសរុបលទ្ធផលការងារប្រតិបត្តិប្រចាំត្រីមាស
- បង្កើនប្រសិទ្ធភាពនៃការបង្រៀន និងរៀន តាមរយៈការបំប៉នសមត្ថភាពនាយកសាលា និងប្រធានក្រុមបច្ចេកទេសលើភាពជាអ្នកដឹកនាំ និងគ្រប់គ្រង
- ការលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពអប់រំ តាមរយៈសាលាមធ្យមសិក្សាធនធាន និងបណ្ដាញ
- ការផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅមធ្យមសិក្សាបានធានាសមធម៌ និងគុណភាពអប់រំជាពិសេសសិស្សស្រី
- កិច្ចសហការជិតស្និទ្ធជាមួយមាតាបិតា អាណាព្យាបាល និងសហគមន៍ជួយគាំទ្រដល់អភិបាលកិច្ចល្អ។

## ២.៤ ការងារតម្រង់ទិសវិជ្ជាជីវៈ

- សិស្សវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសបាននិងកំពុងបណ្ដុះបណ្ដាលអប់រំបច្ចេកទេស ៦៥៣ នាក់ ស្រី ៣៦,១៧ ភាគរយ
- សិស្សអប់រំបច្ចេកទេសវិទ្យាល័យកំពង់ឈើទាលបានប្រឡងបញ្ចប់ ១១៥ នាក់ ស្រី ៣៣,៩ ភាគរយ
- គោលនយោបាយស្ដីពីការអប់រំបច្ចេកទេសបានអនុម័ត និងផ្សព្វផ្សាយ
- វិញ្ញាបនបត្របណ្ដោះអាសន្ន និងសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣
- ឯកសារអប់រំតម្រង់ទិសវិជ្ជាជីវៈសម្រាប់មធ្យមសិក្សាបឋមភូមិបានផលិត និងផ្សព្វផ្សាយ
- សមត្ថភាពមន្ត្រីអប់រំស្ដីពីការអប់រំបច្ចេកទេស ការតម្រង់ទិសវិជ្ជាជីវៈ និងអប់រំបំណិនជីវិត បានលើកកម្ពស់
- មន្ត្រីជំនាញបានទៅសិក្សា និងដកពិសោធន៍ការងារអប់រំបច្ចេកទេសនៅបរទេស
- កម្មវិធីសិក្សាផ្នែកអប់រំបច្ចេកទេសកម្រិតមធ្យមសិក្សាបានអនុម័ត និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការ។

### បញ្ហាប្រឈម

- កង្វះសៀវភៅ និងឯកសារផ្នែកអប់រំបច្ចេកទេសសម្រាប់គ្រូ និងសិស្ស
- បន្ទប់ និងសម្ភារៈសម្រាប់អនុវត្តកម្មវិធីអប់រំបំណិនជីវិតនៅមានការខ្វះខាត
- កង្វះគ្រូឯកទេសសម្រាប់អនុវត្តមុខវិជ្ជាអប់រំបច្ចេកទេស និងបំណិនជីវិត
- ការគ្រប់គ្រង និងការអនុវត្តកម្មវិធីអប់រំបំណិនជីវិតនៅមានកម្រិត។

**បទពិសោធ**

- មានគោលនយោបាយស្តីពីការអប់រំបច្ចេកទេស
- កិច្ចសហការជិតស្និទ្ធជាមួយអង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍក្នុងការពង្រឹង និងពង្រីកការអប់រំបច្ចេកទេស និងតម្រង់ទិសវិជ្ជាជីវៈ និងអប់រំបំណិនជីវិត។

## ២.៥ ការងារអប់រំក្រៅប្រព័ន្ធ

**កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ** ថ្នាក់អក្ខរកម្មមាន ១ ២៧៧ថ្នាក់ បានអនុវត្តនៅទូទាំងប្រទេស។ គ្រូអក្ខរកម្មមាន ១ ៣១២ នាក់ ស្រី ៣៧,១១ ភាគរយ ក្នុងនោះគ្រូអក្ខរកម្មកិច្ចសន្យា ១ ១៨៨ នាក់ ស្រី ៣៨,២១ ភាគរយ អ្នករៀនមាន ២៩ ៨៥៦ នាក់ ស្រី ៦៦,៦៤ ភាគរយ។ អ្នកសិក្សាបានបញ្ចប់ និងទទួលប័ណ្ណអក្ខរកម្មវិជ្ជាជីវៈ ២៣ ២៧៧ នាក់ ស្មើនឹង ៧៩,០២ ភាគរយ ស្រី ៦៨,៣៥ ភាគរយ ថយ ១៣,៤៣ ភាគរយ។ ក្នុងឆ្នាំ ២០១៣ ក្រសួងបានប្រារព្ធទិវាអក្ខរកម្មជាតិ អន្តរជាតិ ៨កញ្ញា នៅខេត្តស្វាយរៀងក្រោមប្រធានបទ «អក្ខរកម្មរួមចំណែកអភិវឌ្ឍសហគមន៍» អ្នកចូលរួម ១ ១១៧ នាក់ ស្រី ៥៤,៧៦ ភាគរយ។

**កម្មវិធីក្រោយអក្ខរកម្ម** បានអនុវត្តនៅទូទាំងប្រទេស មានបណ្ណាល័យ ៣៩ និងមណ្ឌលអាន ២៩៤ ក្នុងនោះបណ្ណាល័យ ៣៥ និងមណ្ឌលអាន ២៧៩ ដំណើរការ និងអ្នកចូលអាន ១១៤ ៩៣៨ នាក់ ស្រី ៥៩,២២ ភាគរយ ថយ ៣,៤៤ ភាគរយ។

**កម្មវិធីចូលរៀនឡើងវិញ** បានអនុវត្តនៅទូទាំងប្រទេស លើកលែងខេត្តឧត្តរមានជ័យ។ ថ្នាក់បំប៉នមាន ១ ០០៩ គ្រូបំប៉ន ១ ០០៩ នាក់ ស្រី ៣០,១២ ភាគរយ។ សិស្ស ១៧ ៣៩៧ នាក់ ស្រី ៥៥,៩១ ភាគរយ។ សិស្សបានបញ្ចប់កម្មវិធី ១៥ ០៥២ នាក់ ស្រី ៥៥,៩៤ ភាគរយ និងបានបញ្ជូនចូលរៀនក្នុងសាលាចំណេះទូទៅវិញ ១៤ ៨៩៩ នាក់ ស្មើនឹង ៨៥,៦៤ ភាគរយ ស្រី ៥៥,៧០ ភាគរយ ថយ ២៩,៦៨ ភាគរយ។

**កម្មវិធីបង្កើនប្រាក់ចំណូលតាមរយៈមជ្ឈមណ្ឌលសិក្សាសហគមន៍** បានអនុវត្តនៅទូទាំងប្រទេស មានមជ្ឈមណ្ឌលសិក្សាសហគមន៍ ៣៨៨ កើន២៧ ក្នុងនោះ ៣២៣ ដំណើរការ ថ្នាក់ជំនាញមាន ៦៤២ គ្រូជំនាញមាន ៦៦០ នាក់ ស្រី ៤៥,៦០ ភាគរយ។ អ្នកសិក្សាមាន ១០ ៨៩៣ នាក់ ស្រី ៥៨,២៥ ភាគរយ និងបានបញ្ចប់ ៧ ៧០៣ នាក់ ស្មើនឹង ៧០,៧១ ភាគរយ ស្រី ៦២,៤៩ ភាគរយ កើន ២,២០ ភាគរយ។

**កម្មវិធីកែលម្អគុណភាពនៃជីវិតតាមរយៈសាលារៀនចល័ត** បានបង្រៀនអំពីបំណិនជីវិតតាមរយៈរថយន្តចល័ត ១៣លើក នៅ ១៣ខេត្ត មានអ្នកចូលរួម ១ ៨៥៩ នាក់ ស្រី ៧១ ភាគរយ កើន ១,៤៧ ភាគរយ។

**កម្មវិធីសមមូល-បំពេញវិជ្ជា** កម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ បានអនុវត្តនៅរាជធានីភ្នំពេញ ខេត្តព្រះសីហនុ និងសៀមរាបមាន ១៥ថ្នាក់ សិស្សចូលរៀន ៧៥៩ នាក់ ស្រី ៥៥,៤៦ ភាគរយ និងបានបញ្ចប់ ៧៥៩ នាក់ ស្មើនឹង ១០០ ភាគរយ ស្រី ៥៥,៤៦ ភាគរយ ថយ ៦៧,៣១ ភាគរយ។

មធ្យមសិក្សាបឋមភូមិបំពេញវិជ្ជានៅរាជធានីភ្នំពេញ និង ១៦ខេត្ត ថ្នាក់៣៧ សិស្ស ១ ២៦៦ នាក់ ស្រី ១៦,៥៨ ភាគរយ។ បេក្ខជនបំពេញវិជ្ជានិងស្វៃរិនមកប្រឡង ១ ២៣២ នាក់ ស្រី ១៦,២៣ ភាគរយ។ បេក្ខជនប្រឡងជាប់ ៧៩៧ នាក់ ស្មើនឹង ៦៤,៦៩ ភាគរយ ស្រី ២០,២០ ភាគរយ ថយ ៩,៣២ ភាគរយ។

មធ្យមសិក្សាទុតិយភូមិបំពេញវិជ្ជាមានថ្នាក់ ១៤៣ សិស្ស ១០ ៩៧០ នាក់ ស្រី ៣៤,៦០ ភាគរយ នៅរាជធានីភ្នំពេញ និង ២១ខេត្ត លើកលែងខេត្តកែប មណ្ឌលគិរី និងប៉ៃលិន។ បេក្ខជនបំពេញវិជ្ជា និងស្វ័យរៀនមកប្រឡង ១១ ១៧៨ នាក់ ស្រី ៣៥,៤៣ ភាគរយ បេក្ខជនប្រឡងជាប់ ៨ ២២០ នាក់ ស្មើនឹង ៧៣,៥៣ ភាគរយ ស្រី ៣៨,២០ ភាគរយ កើន ១៥,០៤ ភាគរយ។

### បញ្ហាប្រឈម

- សម្ភារៈបង្រៀន និងរៀនសម្រាប់ទ្រទ្រង់ដំណើរការថ្នាក់អក្ខរកម្មពុំទាន់ឆ្លើយតបនឹងតម្រូវការ
- ការប្រមូលសិស្សបោះបង់ការសិក្សាឱ្យចូលរៀនឡើងវិញជួបការលំបាក
- គណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍មិនទាន់មានប្រាក់លើកទឹកចិត្ត
- កង្វះគ្រូជំនាញមុខរបរសម្រាប់មជ្ឈមណ្ឌលសិក្សាសហគមន៍មួយចំនួន
- កម្មវិធីសិក្សាអក្ខរកម្មវិជ្ជាជីវៈមិនសូវមានភាពទាក់ទាញក្រុមមុខសញ្ញា
- កង្វះបណ្ណារក្សសម្រាប់ការងារអប់រំក្រៅប្រព័ន្ធ។

### បទពិសោធ

- គោលនយោបាយអប់រំក្រៅប្រព័ន្ធមានផែនការសកម្មភាពសម្រាប់អនុវត្តជាក់លាក់
- ការងារអប់រំក្រៅប្រព័ន្ធបានផ្សព្វផ្សាយ តាមរយៈស្ថានីយវិទ្យុ ទូរទស្សន៍ តាមផ្ទាំងរូបភាព និងប័ណ្ណផ្ទត់
- មន្ត្រីអប់រំក្រៅប្រព័ន្ធគ្រប់លំដាប់ថ្នាក់បានលើកកម្ពស់សមត្ថភាពជាប្រចាំ
- ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធបានរៀបចំ
- អនុក្រុមការងារបច្ចេកទេសអប់រំក្រៅប្រព័ន្ធមានដំណើរការល្អ
- កិច្ចសហការល្អជាមួយអាជ្ញាធរដែនដី ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងសហគមន៍មូលដ្ឋាន។

## ២.៦ ការងារឧត្តមសិក្សា

គ្រឹះស្ថានឧត្តមសិក្សាមាន ១០៥ កើន៤ (គ្រឹះស្ថានឯកជន) ធៀបនឹងឆ្នាំ២០១២។ ក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សាទាំង ១០៥ មានគ្រឹះស្ថានឧត្តមសិក្សារដ្ឋ ៣៩ និងឯកជន ៦៦ ដែលមានទីតាំងនៅតាមរាជធានី ខេត្ត ១៩។ គ្រឹះស្ថានឧត្តមសិក្សា៦៥ (រដ្ឋ៩ និងឯកជន ៥៦) ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា និង ៤០ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង ស្ថាប័ន ១៣ ផ្សេងទៀត។

និស្សិតកំពុងសិក្សាសរុប ២៥៣ ៧៦៤ នាក់ កើន ៩,៤៥ ភាគរយ ស្រី ៤០,១២ ភាគរយ កើន ១០,៤៧ ភាគរយ ក្នុងនោះបរិញ្ញាបត្រ ២២៩ ៤១៤ នាក់ កើន ៩,៤៨ ភាគរយ ស្រី ៤០,៥៨ ភាគរយ កើន ១០,៣៥ ភាគរយ (និស្សិតអាហារូបករណ៍ ២៨ ៣៤៨ នាក់ កើន ៤,៩៨ ភាគរយ ស្រី ៣៦,៤៦ ភាគរយ កើន ២,៥៤ ភាគរយ និងសិក្សាបង់ថ្លៃ ២០១ ០៦៦ នាក់ កើន ១០,១១ ភាគរយ ស្រី ៤១,១៦ ភាគរយ កើន ១១,៣៣ ភាគរយ) និងបរិញ្ញាបត្ររង ២៤ ៣៥០ នាក់ កើន ៩,១៥ ភាគរយ ស្រី ៣៥,៨០ ភាគរយ កើន ១១,៧៧ ភាគរយ (អាហារូបករណ៍ ៤ ១០៣ នាក់ កើន ១៤,៤០ ភាគរយ ស្រី ៣៧,២៩ ភាគរយ កើន ១២,១៦ ភាគរយ និងសិក្សាបង់ថ្លៃ ២០ ២៤៧ នាក់ កើន ៨,០៨ ភាគរយ ស្រី ៣៥,៥០ ភាគរយ កើន ១១,៦៩ ភាគរយ)។

និស្សិតប្រឡងបញ្ចប់ការសិក្សា ៤៨ ៥៤៩ នាក់ កើន ៦,៥៤ ភាគរយ ស្រី ៤០,៦៩ ភាគរយ កើន ៧,២៦ ភាគរយ ក្នុងនោះបរិញ្ញាបត្រ ៣៧ ៧៧៩ នាក់ កើន ៧,៤១ ភាគរយ ស្រី ៤១ ភាគរយ កើន ៦,៨២ ភាគរយ (អាហារូបករណ៍ ៤ ៩៨១ នាក់ កើន ២,៥៣ ភាគរយ ស្រី ៤៤,៤១ ភាគរយ កើន ២,៣១ ភាគរយ និងបង់ថ្លៃសិក្សា ៣២ ៧៩៨ នាក់ កើន ៨,១៦ ភាគរយ ស្រី ៤០,៤៨ ភាគរយ កើន ៧,៥៧ ភាគរយ) និង និស្សិតបរិញ្ញាបត្ររង ១០ ៧៧០ នាក់ កើន ៣,៤៨ ភាគរយ ស្រី ៣៩,៦១ ភាគរយ កើន ៨,៨៨ ភាគរយ (អាហារូបករណ៍ ១ ៨៥០ នាក់ កើន ៦,៧០ ភាគរយ ស្រី ៤៦,៧៦ ភាគរយ កើន ១១,២១ ភាគរយ និងសិក្សាបង់ថ្លៃ ៨ ៩២០ នាក់កើន ២,៨១ ភាគរយ ស្រី ៣៨,១៣ ភាគរយ កើន ៨,២៩ ភាគរយ) ។

ទន្ទឹមនឹងបរិមាណនិស្សិតកើនឡើង ក្រសួងអប់រំ យុវជន និងកីឡា និងគ្រឹះស្ថានឧត្តមសិក្សាបានខិតខំយកចិត្តទុកដាក់ពង្រឹងគុណភាពបណ្ដុះបណ្ដាល ដែលជាកត្តាកំណត់ជោគជ័យសម្រាប់ប្រកួតប្រជែងការងារក្នុងប្រទេសនិងតំបន់។ សកម្មភាពសំខាន់ៗដែលសម្រេចបានមានដូចខាងក្រោម៖

- បានពង្រឹងគុណភាពអប់រំផ្ទៃក្នុង ៨៣គ្រឹះស្ថានឧត្តមសិក្សា ដើម្បីជំរុញឱ្យគ្រឹះស្ថានសិក្សាទាំងនោះអនុវត្តតាមប្រកាស ១៨៣៥ អយក.ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៧ ស្ដីពីលក្ខខណ្ឌ និងលក្ខណវិនិច្ឆ័យលម្អិត សម្រាប់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សាប្រកបដោយគុណភាព និងសមត្ថភាព
- បានលើកកម្ពស់សមត្ថភាពអ្នកគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា តាមរយៈសិក្ខាសាលាស្ដីពីការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំសម្រាប់គ្រឹះស្ថានឧត្តមសិក្សាដែលពាក់ព័ន្ធទាំងអស់
- បានពង្រីកការងារសហប្រតិបត្តិការរវាងគ្រឹះស្ថានឧត្តមសិក្សាក្នុង និងក្រៅប្រទេសចំនួន ៨
- បានបន្តណែនាំគ្រឹះស្ថានឧត្តមសិក្សាមួយចំនួនឱ្យប្រើ និងកែតម្រូវឈ្មោះមហាវិទ្យាល័យ មុខជំនាញឱ្យបានត្រឹមត្រូវតាមច្បាប់អនុញ្ញាត
- បានទទួលស្គាល់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជន ៤
- បានចេញសេចក្ដីសម្រេច ការទទួលស្គាល់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន២ ការប្ដូរឈ្មោះមហាវិទ្យាល័យ និងការបើកមុខជំនាញថ្មី៣ និងការទទួលស្គាល់ក្រុមប្រឹក្សាភិបាល១
- បានចុះត្រួតពិនិត្យវាយតម្លៃសកម្មភាពគម្រោងតាមសមាសភាគនីមួយៗ
- បានអភិវឌ្ឍសមត្ថភាពមន្ត្រីទទួលបន្ទុកព័ត៌មានវិទ្យាស្ដីពីការអភិវឌ្ឍទិន្នន័យ ៧ នាក់។

### បញ្ហាប្រឈម

- ភាពខុសគ្នារវាងតម្រូវការរបស់ទីផ្សារការងារជាមួយនឹងសមត្ថភាពជំនាញរបស់បរិញ្ញាជន ដែលបានបញ្ចប់ការសិក្សា
- គុណវុឌ្ឍិសាស្ត្រាចារ្យ និង សមត្ថភាពមន្ត្រីគ្រប់គ្រងនៅមានកម្រិត
- អភិបាលកិច្ច និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា។

### បទពិសោធ

- សមត្ថភាពមន្ត្រីជំនាញមានការអភិវឌ្ឍ
- និស្សិត និងសាស្ត្រាចារ្យមានការផ្លាស់ប្ដូរគ្នាលើការសិក្សា ការងារបង្រៀន និងការងារស្រាវជ្រាវ
- ការគ្រប់គ្រង និងការបែងចែកអាហារូបករណ៍សិស្ស និស្សិតប្រកបដោយតម្លាភាព។

## ២.៧ ការងារស្រាវជ្រាវវិទ្យាសាស្ត្រ

- គ្រឹះស្ថានឧត្តមសិក្សា ៣៥ ដែលបាននិងកំពុងបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រ ក្នុងនោះគ្រឹះស្ថានសិក្សាឯកជនកើន៤ (សាធារណៈ ៨ និងឯកជន ២៧)។ គ្រឹះស្ថានឧត្តមសិក្សាដែលបាននិងកំពុងបណ្តុះបណ្តាលថ្នាក់បណ្ឌិត មាន ១៥ (សាធារណៈ១ និងឯកជន ១៤)
- បានចេញប្រកាសអនុញ្ញាតឱ្យគ្រឹះស្ថានឧត្តមសិក្សាឯកជន ៤ និងសាធារណៈ ១ ធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់
- បានបោះពុម្ពកម្រងព័ត៌មានស្តីពីការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រ
- និស្សិតកំពុងសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រ ១៧ ៧៣៩ នាក់ កើន ១០,៥២ ភាគរយ ស្រី ១៩,១៤ ភាគរយ កើន ១៥,៤០ ភាគរយ ក្នុងនោះថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ១៦ ៦៥៦ នាក់ កើន ១១,០៦ ភាគរយ ស្រី ២០,០៥ ភាគរយ កើន ១៥,៧៧ ភាគរយ និងថ្នាក់បណ្ឌិត ១ ០៨៣ នាក់ កើន ១,៨៨ ភាគរយ ស្រី ៥,០៨ ភាគរយ ថយ ៣,៥១ ភាគរយ
- និស្សិតបានបញ្ចប់ការសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រ ៣ ៤៨៨ នាក់ ថយ ៣៦,៤៨ ភាគរយ ស្រី ២១,៧២ ភាគរយ ក្នុងនោះបរិញ្ញាបត្រជាន់ខ្ពស់ ៣ ៤៣១ នាក់ ថយ ៣៦,២៤ ភាគរយ ស្រី ២១,៧៧ ភាគរយ ថយ ៣៨,៣៩ ភាគរយ (និស្សិតដែលបានសរសេរនិក្ខេបបទបញ្ចប់ការសិក្សាមាន ៥៤ នាក់ ថយ ៥៧,៤៨ ភាគរយ ស្រី ១១,១១ ភាគរយ ថយ ៧៩,៣១ ភាគរយ) និងថ្នាក់បណ្ឌិតមាន ១៧ នាក់ ថយ ៦៣,៨៣ ភាគរយ ស្រី ១១,៧៦ ភាគរយ កើន ១០០ ភាគរយ
- បានរៀបចំសេចក្តីព្រាងស្តីពីគោលការណ៍លម្អិតនៃការបណ្តុះបណ្តាលថ្នាក់បណ្ឌិត
- បានរៀបចំសន្និសីទអន្តរជាតិលើកទី២ ស្តីពីគណិតវិទ្យា និងការប្រើប្រាស់បច្ចេកវិទ្យាក្នុងការអប់រំគណិតវិទ្យាសិក្ខាកាម ២៥០ នាក់ ស្រី ២០ ភាគរយ។

### បញ្ហាប្រឈម

- សមត្ថភាពមន្ត្រីមួយចំនួននៅមានកម្រិតផ្នែកគ្រប់គ្រង ផែនការ ការស្រាវជ្រាវ និងភាសាបរទេស
- គ្រឹះស្ថានឧត្តមសិក្សាភាគច្រើនមិនទាន់បានយកចិត្តទុកដាក់លើការងារស្រាវជ្រាវ
- ធនធានសាស្ត្រាចារ្យ និងមូលដ្ឋានសម្ភារៈមិនទាន់សមាមាត្រទៅនិងចំនួននិស្សិត។

### បទពិសោធ

- មានកិច្ចសហប្រតិបត្តិការល្អជាមួយគ្រឹះស្ថានសិក្សាក្នុងតំបន់ និងពិភពលោក
- មានលិខិតបទដ្ឋានសម្រាប់គ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រ និងការស្រាវជ្រាវក្នុងវិស័យអប់រំ
- មានផែនការសកម្មភាពសម្រាប់គាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំ។

## ៣- ការងារកសាងលក្ខខណ្ឌចាំបាច់/ការគ្រប់គ្រងវិស័យ

### ៣.១ ការងារយុវជន

- គ្រូបង្គោលថ្នាក់ក្រុង ស្រុក ខណ្ឌ ៤ ២០០ នាក់ ស្រី ៤៤ ភាគរយ បានលើកកម្ពស់សមត្ថភាពស្តីពីការងារក្រុមប្រឹក្សាយុវជន ការងារក្រុមប្រឹក្សាកុមារ និងសកម្មភាពក្លឹប
- ការងារយុវជន ការងារក្រុមប្រឹក្សាយុវជន និងការងារក្រុមប្រឹក្សាកុមារបានការកែលម្អនៅថ្នាក់រាជធានី ខេត្ត
- ក្រុមប្រឹក្សាកុមារ ៧ ៤២១ ដែលមានសាខា ៣៨ ២០៥ អនុសាខា ២២៦ ៧៥០ សមាជិកមាន ១ ៨៩៦ ៦០៤ នាក់ ស្រី ៤៩ ភាគរយ បានរៀបចំសម្រាប់កុមារពីថ្នាក់ទី៤ ដល់ទី៩
- ក្រុមប្រឹក្សាយុវជន ៨២៧ ដែលមានសាខា ៨ ០១៥ អនុសាខា ៨៦ ២៨៨ សមាជិក ៣៦០ ៥១១ នាក់ ស្រី ៤៣ ភាគរយ បានរៀបចំសម្រាប់យុវជនពីថ្នាក់ទី១០ ដល់ទី១២
- ការប្រជុំបូកសរុបវាយតម្លៃចលនាប្រឡងប្រណាំង ៣ល្អ "កូនល្អ សិស្សល្អ មិត្តល្អ" បានរៀបចំនៅរាជធានី ខេត្ត ១០ កើន ៣ ខេត្ត
- រង្វាន់ និងប័ណ្ណសរសើរបានផ្តល់ដល់យុវជន និងកុមារ ៣២៣ នាក់ ស្រី ៤៩ ភាគរយ ជាសមាជិកក្រុមប្រឹក្សាយុវជន និងកុមារដែលមានស្នាដៃក្នុងសកម្មភាព ៣ល្អ
- យុវជនក្រៅសាលា ឃុំ សង្កាត់ ១០ ២៨៥ នាក់ ស្រី ៣៨ ភាគរយ បានបំប៉នឱ្យយល់ដឹងពីមេរោគអេដស៍ ជំងឺអេដស៍
- គ្រូបង្គោលយុវសហគ្រិនថ្នាក់ជាតិ ៦៤ នាក់ ស្រី ៣០ ភាគរយ បានទទួលការបណ្តុះបណ្តាល
- ខ្លឹមសារនាទីអប់រំយុវជននិងកុមារបានកែលម្អ និងផ្សព្វផ្សាយតាមវិទ្យុជាតិកម្ពុជា
- កម្មវិធីទស្សនកិច្ចសិក្សាបានរៀបចំសម្រាប់កុមារ ១៦០ នាក់ ស្រី ៤៨ ភាគរយ និងយុវជន ៣២០ នាក់ ស្រី ៤៩ ភាគរយ ដើម្បីយល់ដឹងពីសម្បត្តិវប្បធម៌ប្រាង្គប្រាសាទខេត្តសៀមរាប
- ក្រុមប្រឹក្សាយុវជនតាមរាជធានី ខេត្តចំនួន ៣៥០ នាក់ ស្រី ៤៨ ភាគរយ បានចូលរួមបោះជំរំយុវជនថ្នាក់ជាតិលើកទី១៥ ក្រោមប្រធានបទ «យុវជន និងការអភិវឌ្ឍ»
- ការចូលរួមប្រារព្ធខួបលើកទី៦៤ ទិវាកុមារអន្តរជាតិ ១មិថុនា មានកុមារ ១ ០០០ នាក់ កុមារី ៥០ ភាគរយ
- ការប្រារព្ធខួបលើកទី១២ ទិវាអន្តរជាតិសម្រាប់យុវជន ១២សីហា ក្រោមប្រធានបទ « យុវជន និងចំណាកស្រុក: ជំរុញការអភិវឌ្ឍ » មានយុវជនចូលរួម ១ ៣០០ នាក់ ស្រី ៤៦ ភាគរយ
- កុមារ និងយុវជន ៣៦៩ នាក់ ស្រី ៤០ ភាគរយ និងអ្នកដឹកនាំ ១៤ នាក់ ស្រី ២៩ ភាគរយ បានទៅចូលរួមសន្និសីទ សិក្ខាសាលា បោះជំរំ ទស្សនកិច្ចសិក្សា ផ្លាស់ប្តូរបទពិសោធ និងកម្មវិធីផ្សេងៗទៀតនៅបរទេស និងបានទទួលកុមារ និងយុវជនជប៉ុន ៨៨ នាក់ ស្រី ៥១ ភាគរយ។

#### បញ្ហាប្រឈម

- កង្វះធនធាន និងមិនទាន់មានយន្តការសម្រាប់អនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុជនកម្ពុជា
- ការផ្សព្វផ្សាយព័ត៌មានការងារ ការងារស្ម័គ្រចិត្ត មិនទាន់បានទូលំទូលាយ
- ការបំប៉នជំនាញទន់មិនទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់យុវជន។

### បទពិសោធ

- មានគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- មានព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិដើម្បីអភិវឌ្ឍយុវជន
- មានអនុក្រឹត្យស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាន និងក្រុមប្រឹក្សាយុវជនថ្នាក់ក្រសួង ស្ថាប័ន រាជធានី ខេត្ត
- មានសេចក្តីព្រាងផែនការសកម្មភាពជាតិដើម្បីអភិវឌ្ឍយុវជន
- បើកវេទិកាយុវជនស្តីពីតម្រូវការទីផ្សារការងារជាមួយផ្នែកឯកជន។

## ៣.២ ការងារគ្រប់គ្រងមជ្ឈមណ្ឌលយុវជន

- បានអភិវឌ្ឍឯកសារស្រាវជ្រាវពីតម្រូវការការងាររបស់យុវជនចំនួន ១៦ ខេត្ត
- បានបណ្តុះបណ្តាលមន្ត្រីយុវជនស្តីពីការគ្រប់គ្រងមជ្ឈមណ្ឌលយុវជន និងការងារស្ម័គ្រចិត្តសិក្ខាកាម ៦០ នាក់ ស្រី ១៦,៧ ភាគរយ
- បានបណ្តុះបណ្តាលជំនាញខ្លីៗ នៅតាមមជ្ឈមណ្ឌលយុវជន ១៥ខេត្ត សិក្ខាកាម ២ ២៦៦ នាក់ ស្រី ៧០ ភាគរយ
- បានបណ្តុះបណ្តាលយុវជនស្ម័គ្រចិត្តរាជធានីភ្នំពេញ និងខេត្តកែប និងយុវជនស្រុក ៤៨ ស្រុក សិក្ខាកាម ២ ៥០០ នាក់ ស្រី ៣០ ភាគរយ
- បានរៀបចំទស្សនកិច្ចសិក្សាយុវជនស្ម័គ្រចិត្តក្រៅសាលា ១៥០ នាក់ ស្រី ៤០ ភាគរយ នៅខេត្តសៀមរាប
- បានទទួលប្រតិភូយុវជនស្ម័គ្រចិត្តកូរ៉េ ២៧៣ នាក់ ស្រី ៤២,៩ ភាគរយ មកបំពេញបេសកកម្មស្ម័គ្រចិត្ត នៅរាជធានីភ្នំពេញ ខេត្តព្រៃវែង តាកែវ និងសៀមរាប
- បានសហការជាមួយអង្គការសម្ព័ន្ធយុវជនអន្តរជាតិនៅកម្ពុជា រៀបចំបោះជំរំអន្តរជាតិនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាមានយុវជន ២ ០០០ នាក់ ស្រី ៤០ ភាគរយ
- បានសហការជាមួយអង្គការកម្មវិធីអ្នកស្ម័គ្រចិត្តសហប្រជាជាតិ ប្រារព្ធទិវាអន្តរជាតិអ្នកស្ម័គ្រចិត្ត ៥ធ្នូ ២០១៣ នៅវិទ្យាស្ថានជាតិអប់រំអ្នកចូលរួម ៧៥០ នាក់ ស្រី ៤៣,៧ ភាគរយ
- បានសហការជាមួយអង្គការពលកម្មអន្តរជាតិ រៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីយុវជន និងអ្នកស្ម័គ្រចិត្តស្តីពីយុវជន និងការអភិវឌ្ឍសហគ្រាសដែលមានមូលដ្ឋាននៅសហគមន៍។ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីព័ត៌មានទីផ្សារការងារនៅខេត្តសៀមរាប ដោយសហការជាមួយភ្នាក់ងារជាតិការងារនៃប្រទេសស៊ុយអែតអ្នកចូលរួម ៣០ នាក់ ស្រី ២៣,៣ ភាគរយ។

### បញ្ហាប្រឈម

- មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង និងកំពង់ស្ពឺ នៅពុំទាន់មានទីតាំងដីសម្រាប់សាងសង់មជ្ឈមណ្ឌលយុវជន
- ទីតាំងដីមជ្ឈមណ្ឌលយុវជនមួយចំនួនធំមិនទាន់មានរបង និងសាងសង់អគារ
- ធនធានសម្ភារៈ និងធនធានមនុស្សនៅតាមមជ្ឈមណ្ឌលយុវជនរាជធានី ខេត្តនៅមានកម្រិត
- កង្វះព័ត៌មាន និងសមត្ថភាពជំនាញក្នុងការស្វែងរកការងារ និងការបង្កើតមុខរបររបស់យុវជន។

### បទពិសោធ

- មានការកែលម្អឯកសារគោលសម្រាប់បណ្តុះបណ្តាលយុវជនស្ម័គ្រចិត្តជាប្រចាំ
- មានការពង្រីកវគ្គបណ្តុះបណ្តាលជំនាញខ្លីៗ ជំនាញវិជ្ជាជីវៈឆ្លើយតបទៅនឹងតម្រូវការរបស់យុវជន និងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជន
- មានការចូលរួមសហការពីអាជ្ញាធរដែនដី និងសហគមន៍។

## ៣.៣ ការងារអប់រំកាយ និងកីឡាសិស្ស-និស្សិត

- បានផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការប្រកួតកីឡាជ្រើសរើសជើងឯកទូទាំងប្រទេស និងការបង្កើតសមាគមកីឡាសិស្ស និស្សិតរាជធានី ខេត្ត
- បានរៀបចំប្រកួតកីឡាជ្រើសរើសជើងឯកទូទាំងប្រទេសកម្រិតមធ្យមសិក្សាមានកីឡាករ ២ ៦៧០ នាក់ ស្រី ៤០,២២ ភាគរយ
- បានរៀបចំកីឡានិស្សិតឧត្តមសិក្សា និងមធ្យមសិក្សាបច្ចេកទេសមានកីឡាករ ១ ១៨១ នាក់ ស្រី ១៥,៦៦ ភាគរយ
- បានកែលម្អទីលានកីឡាក្នុងគ្រឹះស្ថានបឋមសិក្សា និងមធ្យមសិក្សា ៨៥
- បានលើកកម្ពស់ការអភិវឌ្ឍសមាគមកីឡានៅតាមគ្រឹះស្ថានមធ្យមសិក្សា ២០
- បានបំប៉នសមត្ថភាពមុខវិជ្ជាអប់រំកាយនិងកីឡាដល់គ្រូបឋមសិក្សា និងគ្រូអប់រំកាយនិងកីឡានៅមធ្យមសិក្សា ៣៦៥ នាក់ ស្រី ២០,២៧ ភាគរយ
- បានធ្វើតេស្តកាយសម្បទាកុមារអាយុ ៦ ទៅ ១២ឆ្នាំ នៅ ៥ខេត្តគោលដៅមានសិស្ស ៣ ៥០០ នាក់ ស្រី ៥០ ភាគរយ
- បានជំរុញសកម្មភាពអប់រំកាយ និងកីឡាតាមសាលាបឋមសិក្សាគំរូ ១០ និងសាលាគរុកោសល្យ និងវិក្រឹតការខេត្ត ៥ ដោយសហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន
- បានបោះពុម្ពសៀវភៅគ្រូអប់រំកាយ និងកីឡាសម្រាប់បឋមសិក្សា។

### បញ្ហាប្រឈម

- ការអនុវត្តសកម្មភាព និងការប្រើប្រាស់ម៉ោងអប់រំកាយ និងកីឡានៅតាមសាលារៀនពុំទាន់អនុវត្តពេញលេញ
- គ្រឹះស្ថានសិក្សាមួយចំនួនមិនទាន់មានទីលានកីឡាសមស្របសម្រាប់អនុវត្តសកម្មភាពអប់រំកាយ និង កីឡា
- មន្ទីរអប់រំ យុវជន និងកីឡា ៣ មិនបានរៀបចំការប្រកួតកីឡាថ្នាក់រាជធានី ខេត្ត
- ការចូលរួមពីសហគមន៍នៅមានកម្រិត
- កង្វះសៀវភៅអប់រំកាយ និងកីឡាសម្រាប់គ្រូនៅបឋមសិក្សា។

### បទពិសោធ

- បានរៀបចំការប្រកួតកីឡាជ្រើសរើសជើងឯកទូទាំងប្រទេសសិស្សមធ្យមសិក្សា និងនិស្សិតឧត្តមសិក្សា
- បានរៀបចំតេស្តកាយសម្បទាកុមារចាប់ពីអាយុ ៦ ដល់ ១២ឆ្នាំនៅតាមសាលាគោលដៅ។

## ៣.៤ ការងារអប់រំកាយ និងកីឡា

- បានចេញប្រកាសស្តីពីការអនុញ្ញាតឱ្យគណៈកម្មាធិការប្រតិបត្តិសហព័ន្ធកីឡាជាតិ ៨ បំពេញភារកិច្ចក្នុងអាណត្តិរបស់ខ្លួន
- បានរៀបចំការប្រកួតកីឡាមហាជនជ្រើសរើសជើងឯកថ្នាក់ភូមិភាគ ៩ប្រភេទកីឡា នៅរាជធានីភ្នំពេញ ខេត្តសៀមរាប ក្រចេះ កំពង់ធំ និងព្រះសីហនុមានកីឡាករ ១ ២៩២ នាក់ ស្រី ១១,១៩ ភាគរយ
- បានរៀបចំការប្រកួតកីឡាជ្រើសរើសជើងឯកថ្នាក់ជាតិ ២២ប្រភេទកីឡា មានកីឡាករ ៥ ៥៨៧ នាក់ ស្រី ១៨,៤៩ ភាគរយ
- បានបំប៉នសមត្ថភាពមន្ត្រីជំនាញកីឡា មន្ត្រីគ្រប់គ្រងកីឡា និងមន្ត្រីទទួលបន្ទុកកីឡាចំនួន៣មណ្ឌលភូមិភាគ មានសិក្ខាកាម ១៧៣ នាក់ ស្រី ១,៧៣ ភាគរយ
- បានបញ្ជូនមន្ត្រីបច្ចេកទេស ៥នាក់ ចូលរួមដឹកនាំការប្រកួតកីឡាបាល់ទាត់ពានរង្វាន់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន លើកទី៧
- បានបញ្ជូនមន្ត្រីបច្ចេកទេស ៨ នាក់ ចូលរួមសិក្ខាសាលា និងវគ្គបំប៉នផ្សេងៗនៅបរទេស
- បានបញ្ជូនមន្ត្រី ១០ នាក់ និងកីឡាករ ១៨ នាក់ ទៅចូលរួមការប្រកួតកីឡាអន្តរជាតិ
- បានបញ្ជូនមន្ត្រី និងកីឡាករទៅចូលរួមកម្មវិធីបោះជំរំយុវជនកីឡាឆ្នាំ២០១៣ នៅប្រទេសប្រ៊ុយណេ។

### បញ្ហាប្រឈម

- មិនទាន់មានគោលនយោបាយស្តីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា
- ពុំទាន់មានការចាប់អារម្មណ៍ពីដៃគូអភិវឌ្ឍ
- មិនទាន់មានការចូលរួមពីប្រជាជនបានទូលំទូលាយ។

### បទពិសោធ

- មានយន្តការទទួលខុសត្រូវច្បាស់លាស់
- មានកិច្ចសហប្រតិបត្តិការល្អជាមួយសហព័ន្ធកីឡាជាតិ និងអង្គភាពពាក់ព័ន្ធ
- មានការចែករំលែកបទពិសោធ និងព័ត៌មានពីគ្នាទៅវិញទៅមក។

## ៣.៥ ការងារមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា

- បានទទួលគ្រូបង្វឹក និងកីឡាករ ៣៥១ នាក់ ស្រី ១៩,៣៧ ភាគរយ ពីសហព័ន្ធកីឡាជាតិ ២០ មកហាត់ហ្វឹកហ្វឺនរយៈពេល ៨ខែ ដើម្បីត្រៀមចូលរួមប្រកួតកីឡាស៊ីហ្គេមលើកទី២៧ នៅប្រទេសមីយ៉ាន់ម៉ា និងការប្រកួតកីឡាអន្តរជាតិនានា
- បានបញ្ជូនកីឡាករទៅហ្វឹកហាត់នៅបរទេស ១០ប្រភេទកីឡា ៩៤ នាក់ ស្រី ២៥,៥៣ភាគរយ
- បានចុះកិច្ចព្រមព្រៀងជាមួយបណ្តាប្រទេសជាមិត្ត ទទួលយកគ្រូបរទេសមកបង្ហាត់ក្រុមកីឡាជម្រើសជាតិ
- បានបំប៉នសមត្ថភាពគ្រូបង្វឹក គ្រូជំនួយ និងអនុរក្ស ៧៧ នាក់ ស្រី ១០,៣៨ ភាគរយ ស្តីពីផែនការហាត់ហ្វឹកហ្វឺនមុនយុទ្ធនាការហាត់ហ្វឹកហ្វឺន

- បានបំប៉នអនុរក្ស គ្រូបង្វឹក គ្រូជំនួយនិងកីឡាករ ៧៧ នាក់ ស្រី ១០,៣៨ ភាគរយ ស្តីពីការប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា
- បានបំប៉នគ្រូបង្វឹក គ្រូជំនួយ និងកីឡាករ ១៧៦ នាក់ ស្រី ១៨,១៨ ភាគរយស្តីពីក្រមសីលធម៌របស់គ្រូបង្វឹក និងកីឡាករ មុនចេញទៅប្រកួតកីឡាស៊ីហ្គេមលើកទី២៧ នៅប្រទេសមីយ៉ាន់ម៉ា
- បានទទួលមេដាយ ៤៨ គ្រឿង មាស៨ ប្រាក់១១ និងសំរឹទ្ធ ២៩ ក្នុងការប្រកួតកីឡាស៊ីហ្គេមលើកទី២៧ នៅប្រទេសមីយ៉ាន់ម៉ា
- បានទទួលមេដាយ ៣៤ គ្រឿង មាស៧ ប្រាក់៧ និងសំរឹទ្ធ២០ ក្នុងការប្រកួតកីឡាអន្តរជាតិនានា
- បានប្រគល់ប្រាក់រង្វាន់ជ័យលាភី និងប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលជូនជ័យលាភី គ្រូបង្វឹក គ្រូជំនួយនិងកីឡាករ ៤៧ នាក់ ស្រី ៤៦,៨០ ភាគរយ បានចូលរួមក្នុងការប្រកួតកីឡាអន្តរជាតិនានា
- បានផលិត និងចែកចាយទស្សនាវដ្តីកីឡា ៥លេខ មាន ១០ ០០០ ច្បាប់។

**បញ្ហាប្រឈម**

- ទីលាន និងសម្ភារៈហ្វឹកហាត់មិនទាន់គ្រប់គ្រាន់ និងឆ្លើយតបតាមនិយាមបច្ចេកទេស
- សហព័ន្ធកីឡាជាតិមួយចំនួនពុំទាន់មានផែនការសកម្មភាពហ្វឹកហាត់ច្បាស់លាស់
- សិទ្ធិផលនៃការប្រកួតជ្រើសរើសជើងឯកថ្នាក់ជាតិនៅមានកម្រិត។

**បទពិសោធ**

- មានការផ្លាស់ប្តូរបទពិសោធបច្ចេកទេស និងគ្រូបង្វឹក ជាមួយបណ្តាប្រទេសជាមិត្ត
- មានគោលការណ៍បង្កើនប្រាក់រង្វាន់ចំពោះជ័យលាភីនិងប្រាក់ឧបត្ថម្ភចំពោះគ្រូបង្វឹក គ្រូជំនួយក្នុងការប្រកួតជាលក្ខណៈអន្តរជាតិនានា
- មានកិច្ចសហការល្អជាមួយអង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍនានា។

## ៣.៦ ការងារវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា

- បានបញ្ចប់ការបណ្តុះបណ្តាលគរុសិស្សជំនាន់ទី២១ ចំនួន ១៩៨ នាក់ ស្រី ៣៣,៧៨ ភាគរយ
- បាននិងកំពុងបណ្តុះបណ្តាលគរុសិស្សជំនាន់ទី២២ និងទី២៣ ចំនួន ២៩៩ នាក់ ស្រី ៣៣,៣៣ ភាគរយ
- បាននិងកំពុងកែលម្អកម្មវិធីបណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡា
- បានបំប៉នសមត្ថភាពគ្រូអប់រំកាយនិងកីឡានៅតាមវិទ្យាល័យ និងអនុវិទ្យាល័យ ៣០០ នាក់ ស្រី ៧ ភាគរយ
- បានបកប្រែសៀវភៅវិទ្យាសាស្ត្រកីឡា វិភាគច្បាប់បាល់ទះ ច្បាប់និងមូលដ្ឋានគ្រឹះនៃការលេងកីឡាប៉េតង់ជាភាសាជាតិ
- បានចងក្រងឯកសារចិត្តវិទ្យាកីឡា អត្តពលកម្ម បាល់ទាត់ បាល់ទះ បាល់បោះ លំហាត់ទាញសរសៃ និងវិធីសាស្ត្រកីឡា
- បានចុះពិនិត្យតាមដានការបង្ហាត់បង្រៀនគ្រូអប់រំកាយ និងកីឡា។

**បញ្ហាប្រឈម**

- កង្វះអគារសិក្សា អន្តេវាសិកដ្ឋាន ទីលានហ្វឹកហាត់ និងសម្ភារៈហ្វឹកហាត់
- កង្វះគ្រូឧទ្ទេសជំនាញអប់រំកាយ និងកីឡា
- សាលាមួយចំនួនប្រើប្រាស់គ្រូអប់រំកាយ និងកីឡាមិនត្រូវតាមឯកទេស។

### បទពិសោធ

- កំណែទម្រង់ការប្រឡងជ្រើសរើសគ្រូអប់រំកាយ និងកីឡា
- កិច្ចសហការជិតស្និទ្ធជាមួយមាតាបិតា អាជ្ញាធរដែនដីជួយគាំទ្រដល់ការបណ្ដុះបណ្ដាលគ្រូអប់រំកាយនិងកីឡា
- ការចុះធ្វើកម្មសិក្សានៅតាមសាលារៀនចំណេះទូទៅ។

## ៣.៧ ការងារផែនការ

- បានផលិត និងផ្សព្វផ្សាយស្ថិតិ សូចនាករអប់រំ
- បានប្រមូលទិន្នន័យពីគ្រឹះស្ថានសិក្សាឯកជនចំណេះទូទៅ
- បានរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៤-២០១៦ និងផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៤
- បានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨
- បានរៀបចំកម្មវិធីគាំទ្រវិស័យអប់រំនៃកិច្ចសហប្រតិបត្តិការជាមួយសហភាពអឺរ៉ុប និងស៊ុយអែត
- បានទទួលការយល់ព្រមផ្តល់មូលនិធិភាពជាដៃគូសកលសម្រាប់ការអប់រំលើកទី២
- បានរៀបចំកម្មវិធីវិនិយោគសាធារណៈឆ្នាំ២០១៤-២០១៦
- បានរៀបចំការប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំចំនួន ៤ លើក
- បានរៀបចំ និងផ្សព្វផ្សាយលទ្ធផលអង្គវិបស្សនាអប់រំ
- បានរៀបចំផែនការគោលអភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ២០១៤-២០១៨
- បានរៀបចំរបាយការណ៍ស្ដីពីស្ថានភាពអប់រំ យុវជន និងកីឡា ដើមឆ្នាំសិក្សា កណ្ដាលឆ្នាំសិក្សា និងដំណាច់ឆ្នាំសិក្សា២០១២-២០១៣។

### បញ្ហាប្រឈម

- អង្គភាព ស្ថាប័នមួយចំនួនមិនទាន់អនុវត្តផែនការបានពេញលេញតាមការគ្រោងទុក
- មន្ត្រីទទួលបន្ទុកការងារផែនការតាមអង្គភាព ស្ថាប័នមិនទាន់មានសមត្ថភាពរឹងមាំ
- កង្វះមន្ត្រីជំនាញផែនការ ស្ថិតិនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

### បទពិសោធ

- ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ
- បានរៀបចំរបាយការណ៍ជូនក្រសួង ស្ថាប័នពាក់ព័ន្ធប្រកបដោយគុណភាព និងទាន់ពេលវេលា។

## ៣.៨ ការងារបុគ្គលិក

- បុគ្គលិកអប់រំសរុប ១១២ ៧០៤ នាក់ ស្រី ៤១,៤៨ ភាគរយ កើន ១ ៤៤៣ នាក់
- បុគ្គលិកអប់រំទីស្ដីការក្រសួង ៣ ០០៦ នាក់ ស្រី ២៧,៤៨ ភាគរយ
- បុគ្គលិកអប់រំរាជធានី ខេត្ត ១០៩ ៦៩៨ នាក់ ស្រី ៤១,៨៦ ភាគរយ
- ក្របខណ្ឌគ្រូកិច្ចសន្យាចំណេះទូទៅ គ្រូកិច្ចសន្យាអក្ខរកម្ម ពលករអណ្ដែត និងបុគ្គលិកកិច្ចសន្យា ៣ ៤៨៨ នាក់ ស្រី ៤៣,៦៣ ភាគរយ កើន ០,៩ ភាគរយ

- គ្រូបង្រៀនពីរវេន គ្រូបង្រៀនថ្នាក់គួប ១៦ ៦៦០ នាក់ ស្រី ៣២,៣៣ ភាគរយ កើន ៦,២៩ ភាគរយ
- គ្រូបង្រៀនកម្រិតឧត្តមបង្រៀននៅឧត្តមសិក្សា ៤៦ នាក់ ស្រី ២១,៧៣ ភាគរយ បានជ្រើសរើស
- ការប្រឡងប្តូរក្របខណ្ឌផ្ទៃក្នុង ៨២៨ នាក់ ស្រី ៤២,៦៣ ភាគរយ
- ការប្រកាសតែងតាំងគ្រូបង្រៀនកម្មសិក្សាគ្រប់កម្រិត ៤ ០៨៧ នាក់ ស្រី ៥៩,៤៨ ភាគរយ
- ការបើកវគ្គបំប៉នស្តីពីការគ្រប់គ្រង និងពង្រឹងប្រសិទ្ធភាពធនធានមនុស្សមានសិក្ខាកាម ៦៣២ នាក់ ស្រី ៩,៨១ ភាគរយ
- បុគ្គលិកអប់រំ ៧៨ នាក់ ស្រី ១៤,១០ ភាគរយ បានទៅបណ្តុះបណ្តាលក្រៅប្រទេស
- បុគ្គលិកអប់រំ ៤៣ ៦៩០ នាក់ ស្រី ៣៩,៣៤ភាគរយ បានដំឡើងថ្នាក់តាមវេន
- គ្រូបង្រៀនកម្រិតឧត្តម ១ ៣៥៧ នាក់ ស្រី ៣១,៦៨ ភាគរយ គ្រូបង្រៀនកម្រិតមូលដ្ឋាន ១ ៦១២ នាក់ ស្រី ៥១,២៤ ភាគរយ និងគ្រូបង្រៀនកម្រិតបឋម ២ ៣៤៤ នាក់ ស្រី ៦០,៥៨ ភាគរយ បានតាំងស៊ប់
- បុគ្គលិកអប់រំ ១ ០៩៨ នាក់ បានអនុញ្ញាតច្បាប់លំហែមាតុភាព ច្បាប់ព្យាបាលជំងឺ ៣៧៨ នាក់ ស្រី ៤៦,៨២ ភាគរយ និងច្បាប់ទៅបរទេស ៤៨ នាក់ ស្រី ៦២,៥០ ភាគរយ
- បុគ្គលិកអប់រំ ១ ១០៨ នាក់ ស្រី ៣១,១៣ ភាគរយ បានអនុញ្ញាតច្បាប់ដាក់ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស និងទំនេរគ្មានបៀវត្សបន្ត
- បុគ្គលិកអប់រំ ៨៥៦ នាក់ ស្រី ៣៤,៣៥ ភាគរយ បានប្រកាសលុបឈ្មោះ
- បុគ្គលិកអប់រំ ១៥០ នាក់ ស្រី ១៤,៧០ ភាគរយ បានអនុញ្ញាតច្បាប់ដាក់ឱ្យស្ថិតនៅក្រៅក្របខណ្ឌដើម
- បុគ្គលិកអប់រំក្នុងក្របខណ្ឌ ក្រសួងអប់រំ យុវជន និងកីឡា ៨០៦ នាក់ ស្រី ៣៨,៤៦ ភាគរយ បានប្រកាសផ្លាស់ប្តូរកន្លែងបម្រើការងារ
- បុគ្គលិកអប់រំ ២ ០១៨ នាក់ ស្រី ២៧,៣០ ភាគរយ បានប្រកាសដាក់ឱ្យចូលនិវត្តន៍
- មន្ត្រីគ្រប់គ្រងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ១ ៦៥២ នាក់ ស្រី ១៤,៥៣ ភាគរយ បានប្រកាសតែងតាំង និងផ្ទេរភារកិច្ច
- គ្រូចេញថ្មី ៤ ៧៣១ នាក់ ស្រី ៥៥,៩៧ ភាគរយ បានដាក់ពង្រាយ និងគ្រូ ៣២ នាក់ ស្រី ៣១,២៥ ភាគរយ បានពង្រាយឡើងវិញ (ចំណុចដៅ ១០០ នាក់)
- គ្រូបម្រើការនៅតំបន់ដាច់ស្រយាល ៧ ៩៧១ នាក់ ស្រី ៣៥,៧៨ ភាគរយ បានប្រកាសទទួលស្គាល់ និងតំបន់ជួបការលំបាក ២២ ៩៦៥ នាក់ ស្រី ៣៣,៥១ ភាគរយ។

### បញ្ហាប្រឈម

- ប្រាក់បំណាច់មុខងារបុគ្គលិកអប់រំបម្រើការងាររដ្ឋបាលទាបជាងបុគ្គលិកបង្រៀន
- ការពង្រាយគ្រូចេញថ្មី និងការពង្រាយគ្រូឡើងវិញនៅជួបការលំបាក ដោយប្រាក់លើកទឹកចិត្តមានកម្រិតទាប
- ការគ្រប់គ្រងបុគ្គលិកអប់រំតាមអង្គភាព និងគ្រឹះស្ថានសិក្សាមួយចំនួនពុំទាន់សមស្របតាមការពណ៌នាមុខតំណែង លក្ខណសម្បត្តិមុខតំណែង និងនិយាមកំណត់។

### បទពិសោធ

- ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្សបង្កើនប្រសិទ្ធភាពការងារគ្រប់គ្រងបុគ្គលិក
- គ្រូកម្មសិក្សាទទួលបានប្រាក់បំណាច់មុខងារ និងប្រាក់វិភាជន៍គ្រួសារ ១០០ ភាគរយ។

## ៣.៩ ការងារនីតិកម្ម

- បានរៀបចំ និងពិនិត្យផ្តល់យោបល់លើគោលនយោបាយចំនួន៤ និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់វិស័យអប់រំចំនួន ២៧
- បានផ្សព្វផ្សាយផ្ទាំងរូបភាពច្បាប់ស្តីពីការអប់រំដំណាក់កាលទី២ដល់ថ្នាក់ក្រោមជាតិ
- បានព្រាងគោលនយោបាយស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការវិស័យអប់រំ
- បានរៀបចំរបាយការណ៍ស្តីពីបញ្ជីវិភាគមុខងារវិស័យអប់រំ និងបានពិនិត្យមើលឡើងវិញមុខងារ វិស័យអប់រំ ដើម្បីកំណត់មុខងារសម្រាប់ផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានដំណើរការច្រកចេញចូលតែមួយ ដើម្បីបម្រើសេវាសាធារណៈវិស័យអប់រំ
- បានចងក្រងកម្រងព័ត៌មានសេវាសាធារណៈ និងស្តង់ដារសេវាសាធារណៈចំនួន ៣៣ សេវា
- បានពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងអប់រំដែលត្រូវទៅបម្រើការងារនៅ ក្រុង ស្រុក ខណ្ឌគោលដៅ នៃការិយាល័យច្រកចេញចូលតែមួយ
- បានពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងអប់រំស្តីពីអភិបាលកិច្ចល្អសម្រាប់ពង្រឹងការផ្តល់សេវាសាធារណៈ វិស័យអប់រំ មានសិក្ខាកាម ៣០៧ នាក់ ស្រី ៨,៨ ភាគរយ
- បានពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងអប់រំស្តីពី នីតិវិធីនៃការស្នើ ឬការតវ៉ា ការប្តឹង និងដំណោះ ស្រាយសម្រាប់អ្នកសិក្សា មាតាបិតា ឬ អ្នកអាណាព្យាបាល និងបុគ្គលិកអប់រំ មានសិក្ខាកាម ២៨០ នាក់ ស្រី ១៦,៨ ភាគរយ
- បានពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងអប់រំស្តីពី ក្របខណ្ឌច្បាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ មានសិក្ខាកាម ៣៦៦ នាក់ ស្រី ២០,៥ ភាគរយ
- បានចុះពិនិត្យតាមដានលើការអនុវត្តច្បាប់ស្តីពីការអប់រំ និងអនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈ គ្រូបង្រៀនចំនួន ១៥ខេត្ត
- បានចុះពិនិត្យតាមដានលើការផ្តល់សេវាអប់រំផ្អែកលើគោលការណ៍អភិបាលកិច្ចល្អចំនួន ១៤ខេត្ត
- បានចុះពិនិត្យតាមដានវិវាទបុគ្គលិកអប់រំទាំងក្នុង និងក្រៅប្រព័ន្ធតុលាការចំនួន ១២ខេត្ត។

### បញ្ហាប្រឈម

- ការទទួលខុសត្រូវរបស់អង្គភាព ស្ថាប័នមួយចំនួនក្នុងការរៀបចំគោលនយោបាយ និងលិខិត បទដ្ឋានគតិយុត្តនៅមានកម្រិត
- ការយល់ដឹងលើការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការវិស័យអប់រំនៅមិនទាន់ច្បាស់លាស់
- ការរៀបចំយន្តការ និងនីតិវិធីផ្ទេរមុខងារជូនរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវការពេលវេលា និង បទពិសោធ។

បទពិសោធ

- មានបញ្ជីវិភាគមុខងារវិស័យអប់រំដែលកំណត់អំពីមុខងារ និងភារកិច្ចថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- មានកិច្ចសហការល្អជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ
- មានក្រុមការងាររៀបចំ និងពិនិត្យផ្តល់យោបល់លើគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត។

## ៣.១០ ការងារហិរញ្ញវត្ថុ

- បានរៀបចំផែនការចំណាយរយៈពេលមធ្យមឆ្នាំ២០១៤-២០១៦ និងគម្រោងថវិកាឆ្នាំ២០១៤
- បានអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២
- បានចេញប្រកាសអន្តរក្រសួងស្តីពីការបង្កើតរជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធី និងបានតែងតាំងផ្លាស់ប្តូររជ្ជទេយ្យកររជ្ជទេយ្យកររងបុរេប្រទាន សម្រាប់អនុវត្តថវិកាកម្មវិធីជូនអង្គភាពថ្នាក់ជាតិ និងក្រោមជាតិ
- បានតែងតាំងអាណាប័កផ្ទេរសិទ្ធិសម្រាប់ថវិកាកម្មវិធី និងថវិកាមិនមែនកម្មវិធីជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- បានផ្ទេរថវិកាកម្មវិធីជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- បានបំប៉នប្រធានគណនេយ្យ គណនេយ្យករ-គណនេយ្យកររងគ្រប់រាជធានី ខេត្តស្តីពីការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ និងផ្លាស់ប្តូរបទពិសោធក្នុងការអនុវត្តថវិកាទូទៅរបស់រដ្ឋ
- បានបំប៉នគណៈកម្មការទ្រទ្រង់សាលារៀនមូលដ្ឋាន និងគណៈកម្មការគ្រប់គ្រងជំនួយថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ស្តីពីការណែនាំអនុវត្តកម្មវិធីជំនួយដើម្បីកែលម្អសាលារៀន
- បានប្រមូលព័ត៌មានស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីកែលម្អ និងធ្វើបច្ចុប្បន្នកម្មសៀវភៅណែនាំការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់អនុវត្តថវិកាកម្មវិធីជំនួយកែលម្អសាលារៀន
- បានផ្សព្វផ្សាយ និងអនុវត្តប្រកាសអន្តរក្រសួងលេខ ៥០៨ សហវ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣ ស្តីពីគោលការណ៍ចំណាយសម្រាប់អនុវត្តថវិកាកម្មវិធី
- បានឆ្លងសេចក្តីព្រាងអនុក្រឹត្យស្តីពីអាហារូបករណ៍ និងរបបឧបត្ថម្ភជីវភាពអន្តេវាសិក ចុងក្រោយដើម្បីដាក់ចូលកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
- បានចុះពិនិត្យតាមដាន និងណែនាំការគ្រប់គ្រងថវិកាជាតិ និងថវិកាជំនួយ
- បានអនុវត្តនីតិវិធីលទ្ធកម្មថវិកាជាតិចំនួន ៦៧គម្រោង
- បានពង្រឹងការអនុវត្តគោលនយោបាយចំណូល និងចំណាយ
- បានពង្រឹងការរៀបចំថវិកាកម្មវិធី និងត្រៀមលក្ខណៈអនុវត្តថវិកាកម្មវិធីពេញលេញនាឆ្នាំ២០១៥
- បានពង្រឹងការអនុវត្តចំណាត់ថ្នាក់ថវិកានិងគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ
- បានផ្សព្វផ្សាយនីតិវិធីនៃការអនុវត្តថវិកាកម្មវិធី
- បានពង្រឹង និងពង្រីកការប្រើប្រាស់ប្រព័ន្ធធនាគារ
- បានរៀបចំប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ

- បានចំណាយថវិកាកម្មវិធី និងថវិកាមិនមែនកម្មវិធីដោយបោះផ្សាយអាណត្តិបើកប្រាក់សរុប ១ ០៥៦ ៩៦៨ ៨០០ ០០០ រៀល ស្មើនឹង ៩៣,៥៦ ភាគរយ នៃឥណទានកែតម្រូវ ១ ១២៩ ២១៤ ៨០០ ០០០ រៀល។

### បញ្ហាប្រឈម

- អង្គភាពមួយចំនួនរៀបចំផែនការសកម្មភាព និងផែនការចំណាយថវិកាមិនទាន់មានសង្គតិភាពជាមួយនឹងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា
- ការណែនាំថវិកាកម្មវិធីរបស់អង្គភាពថ្នាក់ជាតិមួយចំនួនបញ្ជូនទៅថ្នាក់ក្រោមជាតិមិនទាន់ពេល
- ការអនុវត្តថវិកាមិនមែនកម្មវិធីនៅក្នុងជំពូក និងគណនីតែមួយ មិនអាចធ្វើនិយ័តភាពបាន
- នីតិវិធីឆ្លងឯកសារហិរញ្ញវត្ថុនៅមានភាពស្មុគស្មាញ
- ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យានៅមានកម្រិត។

### បទពិសោធ

- មានការយល់ដឹងពីការគ្រប់គ្រងនិងការប្រើប្រាស់ថវិកាកាន់តែប្រសើរជាងមុន
- មានរចនាសម្ព័ន្ធ បំណែងចែកភារកិច្ច និងការទទួលខុសត្រូវច្បាស់លាស់ក្នុងអង្គភាព
- មានទំនាក់ទំនង និងសហការល្អជាមួយអង្គភាពជំនាញ និងក្រសួង ស្ថាប័នពាក់ព័ន្ធ
- បង្កើនប្រសិទ្ធភាពគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា។

## ៣.១១ ការងារអភិវឌ្ឍន៍កម្មវិធីសិក្សា

- បានជាវសៀវភៅសិក្សាគោលថ្នាក់ទី១ ដល់ទី១២ គ្រប់មុខវិជ្ជាសរុប ៣ ៧៥៣ ០០០ច្បាប់
- បានផ្តល់សៀវភៅសិក្សាគោលសិស្សបឋមសិក្សាថ្នាក់ទី១ ដល់ទី៣ ចំនួន ២,៧ ក្បាល (ចំណុចដៅ ៣ក្បាល សម្រាប់សិស្ស ១នាក់)
- បានផ្តល់សៀវភៅសិក្សាគោលសិស្សបឋមសិក្សាថ្នាក់ទី៤ ដល់ទី៦ ចំនួន ៣,៩៧ ក្បាល (ចំណុចដៅ ៤ក្បាល សម្រាប់សិស្ស ១នាក់)
- បានផ្តល់សៀវភៅសិក្សាគោលសិស្សមធ្យមសិក្សាបឋមភូមិថ្នាក់ទី៧ ដល់ទី៩ ចំនួន ៤ ក្បាល (ចំណុចដៅ ៤ក្បាល សម្រាប់សិស្ស ១នាក់)
- បានផ្តល់សៀវភៅសិក្សាគោលសិស្សមធ្យមសិក្សាទុតិយភូមិថ្នាក់ទី១០ ចំនួន ៧,៨ ក្បាល (ចំណុចដៅ ៨ក្បាល សម្រាប់សិស្ស ១នាក់)
- បានផ្តល់សៀវភៅសិក្សាគោលសិស្សមធ្យមសិក្សាទុតិយភូមិថ្នាក់ទី១១-ទី១២ ចំនួន ៩,៨ ក្បាល (ចំណុចដៅ ១១ក្បាល សម្រាប់សិស្ស ២នាក់)
- បានអភិវឌ្ឍសេចក្តីព្រាងគោលនយោបាយកម្មវិធីសិក្សាចំណេះទូទៅ
- បានផ្គត់ផ្គង់សៀវភៅភាសាអង់គ្លេសសម្រាប់សិស្សថ្នាក់ទី៤
- បានអភិវឌ្ឍស្តង់ដារបណ្ណាល័យមធ្យមសិក្សា
- បានផ្សព្វផ្សាយរបៀបផលិត និងរបៀបប្រើប្រាស់សម្ភារឧបទេស

- បានបើកវគ្គបំប៉នស្តង់ដារកម្មវិធីសិក្សាថ្នាក់ ៣ និងទី៦ ដល់ប្រធានក្រុមបច្ចេកទេស ក្រុមពិនិត្យតាមដាននិងបំប៉នថ្នាក់ក្រុង ស្រុក ខណ្ឌ។

### បញ្ហាប្រឈម

- គោលនយោបាយស្តីពីការអភិវឌ្ឍកម្មវិធីសិក្សាមិនទាន់បានធ្វើបច្ចុប្បន្នកម្ម
- ការអនុវត្តកម្មវិធីសិក្សានៅតាមគ្រឹះស្ថានសិក្សាមួយចំនួនមិនបានពេញលេញ
- សៀវភៅហាមលក់នៅមានលក់ក្នុងទីផ្សារ
- កង្វះមន្ត្រីជំនាញរៀបចំក្របខណ្ឌកម្មវិធីសិក្សា។

### បទពិសោធ

- ពង្រឹងសមត្ថភាពគ្រូលើការអនុវត្តកម្មវិធីសិក្សា កម្មវិធីសិក្សាបំណិនជីវិត និងវិជ្ជាជីវៈជម្រើស
- បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងបណ្ណាល័យ តាមរយៈការបំប៉នសមត្ថភាពបណ្ណារក្ស
- មានស្តង់ដារបណ្ណាល័យសាលារៀនសម្រាប់វាស់វែងក្នុងការអភិវឌ្ឍការងារបណ្ណាល័យ
- បង្កើនម៉ូឌុលអប់រំបំណិនជីវិតបានចំនួន ៣៤។

## ៣.១២ ការងារបណ្តុះបណ្តាល និងមិត្រភាព

- បានបញ្ចប់ការបណ្តុះបណ្តាលគ្រូបង្រៀនគ្រប់ភូមិសិក្សា ៤ ៥៥៧ នាក់ ស្រី ៥៦,៣៧ ភាគរយ
- បាន និងកំពុងបណ្តុះបណ្តាលគរុសិស្សឆ្នាំទី១ និងទី២ ចំនួន ៨ ១៤១ នាក់ ស្រី ៦៤,៧៩ ភាគរយ
- បានបំប៉នគ្រូបឋមសិក្សា និងមត្តេយ្យសិក្សាដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឱ្យទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន ២ ៩៩៤ នាក់ ស្រី ៥៦,២៩ភាគរយ
- បានបំប៉នសមត្ថភាពនាយក នាយករង នាយិកា នាយិការងសាលារៀន ៦៩០ នាក់ ស្រី ១០,៤៣ ភាគរយ
- បានបំប៉នស្តីពីការសិក្សាស្រាវជ្រាវមេរៀនជូនគ្រូឧទ្ទេស និងគ្រូកំពុងបង្រៀនថ្នាក់ទី១២ នៅទូទាំងប្រទេស ២ ៨៦០ នាក់ ស្រី ២២,២៧ ភាគរយ
- បានបំប៉នស្តីពីការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ជូនគ្រូឧទ្ទេស និងគ្រូមធ្យមសិក្សា ២០៣ នាក់ ស្រី ២២,១៦ ភាគរយ
- បានបំប៉នស្តីពីចំណេះដឹងយេនឌ័រជូនមន្ត្រីអប់រំ ២០២ នាក់ ស្រី ៦៣ ,៣៦ ភាគរយ
- បានបំប៉នស្តីពីកម្មវិធីសាលាកុមារមេត្រីសម្រាប់បណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន ៧៦នាក់ ស្រី ៣១,៥៧ ភាគរយ
- បានបំប៉នគ្រូឧទ្ទេសស្តីពីការអប់រំបញ្ចូលគ្នា ៤៧១ នាក់ ស្រី ៣២,៩០ ភាគរយ
- បានបំប៉នឯកសារណែនាំគ្រូបង្រៀនមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ ៣ ៧៥០ នាក់ ស្រី ៣០,៣៥ ភាគរយ
- បានបើកសិក្ខាសាលា និងវគ្គបំប៉នខ្លីៗ ដោយសហការជាមួយដៃគូអភិវឌ្ឍវិស័យអប់រំ ១៥ ២២៥ នាក់ ស្រី ៣៥,១៨ ភាគរយ

- បានបំពាក់សម្ភារៈពហុព័ត៌មាននៅតាមសាលាគរុកោសល្យសម្រាប់ការបង្រៀន និងរៀន
- បានអភិវឌ្ឍគោលនយោបាយគ្រូបង្រៀន។

### បញ្ហាប្រឈម

- មិនទាន់អាចទាក់ទាញបេក្ខជនដែលមានសមត្ថភាពខ្ពស់ឱ្យចូលបម្រើវិជ្ជាជីវៈគ្រូបង្រៀន
- ប្រព័ន្ធវិក្រឹតការទៀងទាត់សម្រាប់គ្រូបង្រៀនមិនទាន់បានអនុវត្ត
- សមត្ថភាពចំណេះដឹង និងវិធីសាស្ត្របង្រៀនរបស់គ្រូឧទ្ទេសនៅមានកម្រិត។

### បទពិសោធ

- មានសម្ភារបរិក្ខារសមស្របសម្រាប់ដំណើរការបណ្តុះបណ្តាល
- មានគោលការណ៍បង្កើនអាហារូបករណ៍គរុសិស្ស គរុនិស្សិត
- មានគោលនយោបាយស្តីពីគ្រូបង្រៀនសម្រាប់អភិវឌ្ឍគ្រូបង្រៀន។

## ៣.១៣ ការងារសុខភាពសិក្សា

- បានចេញសេចក្តីណែនាំស្តីពីការលើកកម្ពស់សុខភាពតាមសាលារៀន
- បានប្រជុំគណៈកម្មាធិការអន្តរនាយកដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀន
- បានបើកសិក្ខាសាលាផ្សព្វផ្សាយទិវាលាងសម្អាតដៃ និងអនាម័យតាមសាលារៀន
- បានបំប៉នបុគ្គលិកអប់រំស្តីពីការគ្រប់គ្រងថវិកាកម្មវិធីលើកកម្ពស់សុខភាពសិក្សា
- បានបំប៉នគ្រូស្តីពីសុខភាពអនាម័យ និងវិធីសាស្ត្រសង្គ្រោះបឋម
- បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការសៀវភៅអប់រំបំណិនជីវិតស្តីពីសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ
- បានចែកសម្ភារៈនិងឯកសារអប់រំស្តីពីការលើកកម្ពស់សុខភាពដល់គ្រូបង្រៀនតាមរាជធានី ខេត្ត
- បានបំប៉នមន្ត្រីអប់រំនិងគ្រូបង្រៀនស្តីពីសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ ៤៣៦ នាក់ ស្រី ៣៥ ភាគរយ
- បានបំប៉នមន្ត្រីអប់រំខេត្តស្តីពីវិធានការបង្ការជំងឺគ្រុនចាញ់ ១១៤ នាក់ ស្រី ៣៨ ភាគរយ ក្នុងខេត្តគោលដៅ ១៤ ដែលមានអត្រាគ្រុនចាញ់ខ្ពស់
- បានបំប៉នគ្រូបឋមសិក្សាស្តីពីការអប់រំសុខភាពមាត់ធ្មេញ ការលាងសម្អាតដៃ និងសម្ភារៈអនាម័យនៅរាជធានី ខេត្តចំនួន ៥ មានអ្នកចូលរួម ១ ៤៣៤ នាក់ ស្រី ៥២ ភាគរយ
- បានបំប៉នគ្រូបឋមសិក្សា ស្តីពីការអប់រំសុខភាពភ្នែកនៅខេត្ត ៥ មានអ្នកចូលរួម ៨ ២៤៨ នាក់ ស្រី ៦០ ភាគរយ
- បានផ្តល់ប្រអប់សង្គ្រោះបឋមដល់សាលាបឋមសិក្សា ៣៣០
- បានពិនិត្យសុខភាពនិងកាយសម្បទាបុគ្គលិកអប់រំនិងអ្នកសិក្សា ៣ ០៦៥ នាក់ ស្រី ៥៩ ភាគរយ
- បានដំណើរការកម្មវិធីលាងសម្អាតដៃ និងដុសសម្អាតមាត់ធ្មេញនៅតាមសាលាបឋមសិក្សា ១០
- បានសហការជាមួយក្រសួងសុខាភិបាលផ្តល់ថ្នាំទម្លាក់ព្រូនចំនួន ២លើក លើកទី១ ចំនួន ១ ៣៩៥ ៩៥៩ នាក់ និងលើកទី២ ចំនួន ១ ០៦៥ ៨២៦ នាក់។

**បញ្ហាប្រឈម**

- សម្ភារបរិក្ខារផ្នែកអនាម័យមិនទាន់ឆ្លើយតបនឹងស្តង់ដារ
- កង្វះប្រអប់សង្គ្រោះបឋមនៅតាមគ្រឹះស្ថានសិក្សា
- កង្វះមន្ត្រីជំនាញផ្នែកបច្ចេកទេសវេជ្ជសាស្ត្រ។

**បទពិសោធ**

- មានសម្ភារបរិក្ខារផ្នែកអនាម័យនៅតាមសាលារៀន
- មានកម្មវិធីអនាម័យគំរូតាមសាលារៀន
- មានកិច្ចសហការល្អជាលក្ខណៈពហុវិស័យជាមួយអ្នកពាក់ព័ន្ធ
- មានការថ្លៃប្រឌិតខ្ពស់លើការអនុវត្តការងារលើកកម្ពស់សុខភាពសិក្សា និងបរិស្ថានសាលារៀន។

## ៣.១៤ ការងាររដ្ឋបាល

- បានទទួលលិខិតចូលពីអង្គភាពក្រោមឱវាទ និងអន្តរក្រសួង ស្ថាប័ន ៩ ៥៣០ ច្បាប់ និងបញ្ជូនលិខិតចេញ ១៦ ៧៨៦ ច្បាប់
- បានសហការជាមួយគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ដើម្បីរៀបចំពិធីផ្សេងៗ
- បានបំប៉នបុគ្គលិកអប់រំ ៤៨៨ នាក់ ស្រី ១៦,១៨ ភាគរយ ស្តីពីការគ្រប់គ្រងបណ្ណសារ និងគ្រប់គ្រងរដ្ឋបាលអប់រំ
- បានចេញប្រកាសស្តីពីការផ្តល់ទង់ជ័យលាភី ១៧០ និងប័ណ្ណសរសើរ ១៥៣
- បានចែកគ្រឿងឥស្សរិយយសការងារជូនបុគ្គលិកអប់រំ ១ ២១៦ នាក់ ស្រី ៣៤,៩១ ភាគរយ និងលើកសំណើសុំគ្រឿងឥស្សរិយយសជូនបុគ្គលិកអប់រំ ៨ ៣៦០ នាក់ ស្រី ៣៣,០០ ភាគរយ
- បានធ្វើរបាយការណ៍បូកសរុបស្តីពីការងារអប់រំ យុវជន និងកីឡាជូនក្រសួង ស្ថាប័នពាក់ព័ន្ធតាមកាលកំណត់
- បានរក្សាទុកលិខិតគ្រប់ប្រភេទនៅថ្នាក់ជាតិឆ្នាំ២០១១ តាមប្រព័ន្ធព័ត៌មានវិទ្យា ១៦ ១៤៩ ច្បាប់
- បានសហការរៀបចំវេទិកាស្តីពីការងារអប់រំ យុវជន និងកីឡា ៩៤៤ នាក់ ស្រី ១៧,៥៨ ភាគរយ។

**បញ្ហាប្រឈម**

កង្វះការលើកទឹកចិត្តបុគ្គលិកអប់រំ តាមរយៈការផ្តល់គ្រឿងឥស្សរិយយសការងារ។

**បទពិសោធ**

- មានលិខិតបទដ្ឋានគតិយុត្តិនិងលិខិតគំរូសម្រាប់ការគ្រប់គ្រងការងាររដ្ឋបាល
- ពង្រឹងសមត្ថភាពលើការគ្រប់គ្រងបណ្ណសារ និងលិខិតរដ្ឋបាល។

## ៣.១៥ ការងារទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍

- បានប្រឡងជ្រើសរើសនិស្សិត ៥៧១ នាក់ ស្រី ២៣,៧០ ភាគរយ ទៅសិក្សានៅបរទេស
- បានទទួលចុះឈ្មោះនិស្សិតបញ្ចប់ការសិក្សាពីបរទេស ១៩៤ នាក់ ស្រី ៩,០២ ភាគរយ

- បានគ្រប់គ្រងនិស្សិតអាហារូបករណ៍បរទេស ១៥១ នាក់ ស្រី ២១,៨៥ ភាគរយ បានទទួលនិស្សិតអាហារូបករណ៍បរទេសថ្មី ៥០ នាក់ ស្រី ៣០ ភាគរយ និងនិស្សិតបរទេសរៀនបង់ថ្លៃ ១៨ នាក់ ស្រី ៣៣,៣៣ ភាគរយ បានសម្រួលឱ្យចូលរៀនទៅតាមមុខវិជ្ជាស្នើសុំ
- បានបំប៉ននិស្សិតអាហារូបករណ៍ទៅសិក្សានៅបរទេសនិងនិស្សិតបរទេសមកសិក្សានៅកម្ពុជាស្តីពីវប្បធម៌ ប្រពៃណី និងការរស់នៅ
- បានចុះផ្សព្វផ្សាយណែនាំអំពីកម្មវិធីអាហារូបករណ៍ទៅសិក្សាបរទេស នៅតំបន់ដាច់ស្រយាលជួបការលំបាក
- បានបញ្ជូនបុគ្គលិកអប់រំ ៤០៩ នាក់ ស្រី ២០,៣ ភាគរយ ចូលរួមប្រជុំ សិក្ខាសាលា និងបណ្តុះបណ្តាលនៅបរទេស
- បានពន្យារទិដ្ឋាការជូនបុគ្គលិកដៃគូអភិវឌ្ឍ ៨១ នាក់ ស្រី ២៩,២៦ ភាគរយ និងសុំពន្ធអាករជាបន្ទុករបស់រដ្ឋជូនអង្គការ ២៦ លើក
- បានធ្វើលិខិតអនុញ្ញាតឱ្យអង្គការ ១១ បានប្រើស្លាកលេខ NGO និង IO សម្រាប់រថយន្ត ១៧ គ្រឿង និងម៉ូតូ ៥៥ គ្រឿង
- បានចុះអនុស្សារណៈនៃការយោគយល់បន្ត ៦១ អង្គការ និងបានធ្វើលិខិតគាំទ្រស្នើសុំឱ្យអង្គការ ៣៩ ដើម្បីចុះអនុស្សរណៈយោគយល់ជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានជូនមេដាយស្ថាបនាជាតិ ១៣៤ គ្រឿង និងលិខិតថ្លែងអំណរគុណ ១៧៤ សន្លឹក ដល់សប្បុរសជន និងដៃគូអភិវឌ្ឍ
- បានបំប៉នមន្ត្រីគ្រប់គ្រងស្តីពីការស្រាវជ្រាវផ្នែករៀន និងបង្រៀនភាសាបារាំងដល់គ្រូភាសាបារាំង ៦០ នាក់ ស្រី ៤៥ ភាគរយ រៀបចំទិវាហ្វ្រង់កូហ្វូនីមានអ្នកចូលរួម ១ ០០០ នាក់ ស្រី ៤៥ ភាគរយ និងសិក្ខាសាលាស្តីពីការស្រាវជ្រាវផ្នែកភាសាបារាំង ជូនក្រុមគ្រូបង្រៀនវ័យក្មេង ២០ នាក់ ស្រី ៥៥ ភាគរយ
- បានទទួលគណៈប្រតិភូក្រសួងអប់រំនៃរដ្ឋភាគខាងលិចប្រទេសអូស្ត្រាលី ក្នុងក្របខណ្ឌសាលាសម្ព័ន្ធមេត្រីនៅខេត្តកំពង់ស្ពឺ។

### បញ្ហាប្រឈម

មានការលំបាកក្នុងការសុំតួលេខនិស្សិតចេញ និស្សិតកំពុងសិក្សា និងនិស្សិតបញ្ចប់ការសិក្សាពីស្ថានទូត និងស្ថានតំណាងផលប្រយោជន៍បរទេសប្រចាំនៅកម្ពុជា។

### បទពិសោធ

- បានរៀបចំការប្រឡងជ្រើសរើសនិស្សិតអាហារូបករណ៍ទៅសិក្សានៅបរទេសទាន់ពេលកំណត់
- បានផ្តល់ឱកាសឱ្យនិស្សិតអាហារូបករណ៍បរទេសបានស្វែងយល់ពីរមណីយដ្ឋានវប្បធម៌ និងទេសចរណ៍កម្ពុជា។

## ៣.១៦ ការងារព័ត៌មាន និងកិច្ចការអាស៊ាន

- បានសហការជាមួយអាជ្ញាធរដែនដី និងមាតាបិតាសិស្សក្នុងយុទ្ធនាការប្រមូលកុមារអាយុ ៦ឆ្នាំ ចូលរៀនថ្នាក់ទី១ នៅតាមតំបន់ដាច់ស្រយាលជួបការលំបាក
- បានចេញផ្សាយព្រឹត្តិបត្រអប់រំលេខ៧ និងលេខ៨
- បានផ្សព្វផ្សាយឯកសារវីដេអូខ្លីស្ដីពីសមិទ្ធផលវិស័យអប់រំ យុវជន និងកីឡា
- បានធ្វើបច្ចុប្បន្នកម្មគេហទំព័រក្រសួងជាភាសាខ្មែរ និងអង់គ្លេស
- បានបំប៉នមន្ត្រីអប់រំ ១០៩ នាក់ ស្រី ២១,១០ ភាគរយ ស្ដីពីកម្មវិធីការិយាល័យភាសាខ្មែរអ៊ីនធឺណិត និងអ៊ីម៉ែល
- បានរៀបចំវេទិកាអន្តរជាតិស្ដីពីបច្ចេកវិទ្យាព័ត៌មានអប់រំឆ្នាំ ២០១៣ និងដាក់ឱ្យដំណើរការថ្នាក់រៀនប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដោយសហការជាមួយក្រសួងអប់រំសាធារណរដ្ឋកូរ៉េ
- បានលើកកម្ពស់សមត្ថភាពបុគ្គលិកអប់រំ តាមរយៈការបណ្ដុះបណ្ដាលកុំព្យូទ័រកម្រិតមូលដ្ឋាន និងកម្រិតមធ្យម ៥០១ នាក់ ស្រី ២៤,៧៥ ភាគរយ
- បានលើកកម្ពស់សមត្ថភាពគ្រូបង្រៀននៅវិទ្យាល័យ និងសាលាគរុកោសល្យពីកម្មវិធី INTEL Teach Program ៤៥៦ នាក់ ស្រី ៣១,៧៩ ភាគរយ
- បានផ្សព្វផ្សាយព័ត៌មានជាតិ និងអន្តរជាតិទាក់ទងទៅនឹងវិស័យអប់រំ យុវជន និងកីឡា ៨១ អត្ថបទ
- បានផ្សព្វផ្សាយសកម្មភាពការងារអប់រំ យុវជន និងកីឡាតាមប្រព័ន្ធផ្សព្វផ្សាយ ១៥០ លើក
- បានសិក្សានិងជូនយោបល់លើឯកសារសហប្រតិបត្តិការវិស័យអប់រំ យុវជន និងកីឡាក្នុងក្របខណ្ឌអាស៊ានស៊ីមេអូ និងពិភពលោក ២៧៩ ឯកសារ
- បានបើកសិក្ខាសាលា ស្ដីពីការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ក្នុងការរៀន និងបង្រៀនដល់គ្រូផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យា ៩០ នាក់ ស្រី ១៧,១០ ភាគរយ
- បានបញ្ជូនបុគ្គលិកអប់រំទៅចូលរួម ប្រជុំ សិក្ខាសាលា និងទស្សនកិច្ចសិក្សាក្នុងក្របខណ្ឌអាស៊ាន-ស៊ីមេអូ ១៨០ នាក់ ស្រី ៩១,៨៥ ភាគរយ
- បានបញ្ជូនសិស្ស និស្សិតចូលរួមកម្មវិធីផ្លាស់ប្ដូរវប្បធម៌ និងបទពិសោធរវាងសិស្ស និស្សិតអាស៊ីបូព៌ា-ជប៉ុន ៦៧ នាក់ ស្រី ៤៦,២៦ ភាគរយ
- បានទទួលពានរង្វាន់មហោស្រពភាពយន្តអន្តរជាតិកុមារអាស៊ីអន្តរជាតិនៅប្រទេសជប៉ុន
- បានបញ្ជូនសិស្ស និស្សិតចូលរួមកម្មវិធីផ្លាស់ប្ដូរសិស្ស និស្សិតក្នុងក្របខណ្ឌអាស៊ាន-ស៊ីមេអូ ២៦ នាក់ ស្រី ៥៧,៨៩ ភាគរយ
- បានព្រាងគោលនយោបាយស្ដីពីការអប់រំពីចម្ងាយ
- បានទទួលគណៈប្រតិភូរដ្ឋមន្ត្រីក្រសួងអប់រំនិងបណ្ដុះបណ្ដាលវៀតណាម ដែលជាប្រធានក្រុមប្រឹក្សាភិបាលរដ្ឋមន្ត្រីអប់រំអាស៊ីអគ្នេយ៍។

### បញ្ហាប្រឈម

ការផ្សព្វផ្សាយព័ត៌មានអប់រំ យុវជន និងកីឡា មិនទាន់ឆ្លើយតបតាមតម្រូវការ។

### បទពិសោធ

- ការងារទំនាក់ទំនងសាធារណៈ និងកិច្ចសហប្រតិបត្តិការល្អលើវិស័យអប់រំ យុវជន និងកីឡា ជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធ
- ការផ្សព្វផ្សាយសមិទ្ធផលអប់រំ យុវជន និងកីឡា តាមប្រព័ន្ធផ្សព្វផ្សាយ និងគេហទំព័រក្រសួង
- ការអនុវត្តផែនការសកម្មភាពបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងវិស័យអប់រំ
- ការអនុវត្តយុទ្ធនាការអប់រំស្តីពីការចុះឈ្មោះរបស់កុមារចូលរៀននៅអាយុ ៦ ឆ្នាំនៅតាមតំបន់ដាច់ស្រយាលជួបការលំបាក
- ការលើកកម្ពស់សមត្ថភាពបុគ្គលិកអប់រំតាមរយៈការបណ្តុះបណ្តាលកុំព្យូទ័រកម្រិតមូលដ្ឋាន និងកម្រិតមធ្យមនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ការងារទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការបានល្អលើវិស័យអប់រំ យុវជន និងកីឡាជាមួយប្រទេសដៃគូក្នុងតំបន់ និងពិភពលោក។

## ៣.១៧ ការងារគ្រប់គ្រងសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ

- បានបំប៉នមន្ត្រីជំនាញ និងនាយកសាលាស្តីពីការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ១ ០៦១ នាក់ ស្រី ១១,៣១ ភាគរយ
- បានធ្វើបែបបទនាំចូល និងចេញដោយពន្ធនិងអាករជាបន្ទុករបស់រដ្ឋជូនអង្គការ និងអង្គភាពក្រោមឱវាទ ១៨ លើក
- បានរៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើងថយចុះឆ្នាំ២០១២ របស់អង្គភាពរដ្ឋបាលកណ្តាលចំនួន ៤៧ ស្មើនឹង ១០០ ភាគរយ និងអង្គភាពរាជធានី ខេត្ត ១៨ ស្មើនឹង ៧៥ ភាគរយ
- បានជម្រះចេញពីបញ្ជីសារពើភ័ណ្ឌនូវអគារចាស់ៗ រថយន្ត សម្ភារបរិក្ខារសរុប ១ ០៩៨ ឯកតា
- បានធ្វើបញ្ជីជាតិដី ៤ ៦៤៩ ទីតាំង ស្មើនឹង ៥៤,៤៦ ភាគរយ និងបញ្ជីអចលនទ្រព្យ ៦៨ ស្មើនឹង ២៣,០៥ ភាគរយ
- បានបង់ចូលថវិការដ្ឋ ១៦៨ ៩៩៨,៧៥ ដុល្លារអាមេរិក តាមរយៈការជួលអចលនទ្រព្យ និងលក់សម្ភារៈចាស់ៗ
- បានពិនិត្យការជួសជុលយានយន្ត ១៧៩ ករណី ធ្វើស្លាកលេខរថយន្ត ៥ គ្រឿង និងម៉ូតូ ១៩ គ្រឿង។

### បញ្ហាប្រឈម

- ការដោះស្រាយវិវាទដីធ្លីពុំទាន់មានប្រសិទ្ធភាពខ្ពស់
- ការធ្វើប័ណ្ណកាន់កាប់អចលនទ្រព្យនៅមានចំនួនតិច
- គណៈកម្មការសារពើភ័ណ្ឌរាជធានី ខេត្តមួយចំនួនពុំបានរៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះតាមកាលកំណត់
- នីតិវិធីជម្រះប្រើរយៈពេលយូរ និងមានបែបបទច្រើន។

### បទពិសោធ

- ការបំប៉ន និងការពិនិត្យតាមដានលើការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋធ្វើឱ្យអង្គភាពប្រើប្រាស់ មានបញ្ជីសារពើភ័ណ្ឌត្រឹមត្រូវ និងលើកគម្រោងតម្រូវការផ្គត់ផ្គង់ចំទិសដៅ
- ការធ្វើបញ្ជីជាតិដីបានកាត់បន្ថយការរំលោភបំពានទៅលើទីតាំងដីដែលជាកម្មសិទ្ធិរដ្ឋ។

## ៣.១៨ ការខារសំណង់សិក្សា

- បានជួសជុល និងសាងសង់ហោដ្ឋារចនាសម្ព័ន្ធរូបវន្តសាកលវិទ្យាល័យ ជា ស៊ីម កំចាយមារខេត្តព្រៃវែង
- បានដាក់ឱ្យប្រើជាផ្លូវការអគារសិក្សា ១ខ្នង មាន ១៨បន្ទប់ នៅវិទ្យាល័យ ហ៊ុន សែន កំចាយមារខេត្តព្រៃវែង
- បានដាក់ឱ្យប្រើជាផ្លូវការអគារសិក្សា ១ខ្នង ៥ជាន់ មាន ៤៨បន្ទប់ នៅវិទ្យាស្ថានជាតិអប់រំ
- បានសាងសង់អគារសិក្សាពីគម្រោងនានា ១២៣ ខ្នង
- បាននិងកំពុងសាងសង់អគាររដ្ឋបាលក្រសួងសម្រេចបាន ៦៥ភាគរយ និងមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡាសម្រេចបាន ៣៥ ភាគរយ
- បានដាក់ឱ្យប្រើជាផ្លូវការអគារសិក្សា ១ខ្នង មាន ១០បន្ទប់ នៅវិទ្យាល័យ ព្រះបាទនរោត្តម ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង
- បានជួសជុលកែលម្អអគាររដ្ឋបាល ទីលានកីឡា និងប្រព័ន្ធទឹកនៅពហុកីឡដ្ឋានជាតិសម្រេចបាន ៩៨ ភាគរយ
- បានបញ្ចប់ការជួសជុល និងសាងសង់អគារសិក្សា ១៣ ខ្នង មាន ៨៩ បន្ទប់ ដែលរងផលប៉ះពាល់ដោយខ្យល់ព្យុះ
- បានសាងសង់អគារធនធាន ១០ មជ្ឈមណ្ឌលធនធាន ៤ អគារអន្តេវាសិកដ្ឋាននារី ២ មាន ១០ បន្ទប់ និងបង្គន់អនាម័យនារី ៥៣ ខ្នង មាន ២៦៥ បន្ទប់
- បាននិងកំពុងសាងសង់អគារសិក្សា ១៥ ខ្នង មាន ១២២ បន្ទប់
- បានលើកកម្ពស់សមត្ថភាពមន្ត្រីអប់រំលើការងារគ្រប់គ្រងហោដ្ឋារចនាសម្ព័ន្ធអប់រំ ១ ៧១៩ នាក់ ស្រី ១៥ ភាគរយ។

សំណង់អគារសិក្សាដែលជាអំណោយដ៏ថ្លៃថ្លារបស់ □□□□□□□□□□□□□□□□□□□□ □□□□ **ហ៊ុន សែន** □□□□□□□□□□□□□□□□□□□□□□□□□□□□□□□□□□□□□□ □□□សម្តេចកិត្តិ□□□□□□□□□□□□□□ **ប៊ុន រ៉ានី ហ៊ុន សែន** មាន ៣ ៧០៥ ខ្នង ស្មើនឹង ១៩ ៣១៩ បន្ទប់ គិតត្រឹមថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ ដោយឡែកនៅរាជធានីភ្នំពេញសាងសង់អគារសិក្សាបាន ១២៥ ខ្នង ស្មើនឹង ៧៧១ បន្ទប់។

### បញ្ហាប្រឈម

- ពុំទាន់មានលទ្ធភាពជួសជុលអគារសិក្សាដែលមានសភាពទ្រុឌទ្រោម
- មិនទាន់បានដោះស្រាយសំណើសុំសាងសង់ និងជួសជុលហោដ្ឋារចនាសម្ព័ន្ធអប់រំ
- ការថែទាំហោដ្ឋារចនាសម្ព័ន្ធអប់រំតាមគ្រឹះស្ថានសិក្សានៅមានកម្រិត។

**បទពិសោធ**

- មានកិច្ចសហប្រតិបត្តិការល្អជាមួយអង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ
- មានយន្តការគ្រប់គ្រងការងារសំណង់ប្រកបដោយប្រសិទ្ធភាព។

## ៣.១៩ ការងារបោះពុម្ព និងចែកផ្សាយ

- បានអភិវឌ្ឍសៀវភៅសិក្សាគោលសម្រាប់សិស្សថ្នាក់ទី១១ និងទី១២ ចំនួន ៨មុខវិជ្ជា
- បានអភិវឌ្ឍសៀវភៅសិក្សាគោលសម្រាប់គ្រូថ្នាក់ទី៦ និងទី៩ ចំនួន ៨ មុខវិជ្ជា
- បានអភិវឌ្ឍសៀវភៅហ្វឹកហាត់គណិតវិទ្យាថ្នាក់ទី៤ សរសេរតាមអាន និងតែងសេចក្តីថ្នាក់ទី៤ ដល់ទី៧ ចំនួន ៥មុខវិជ្ជា និងសៀវភៅអំណានបន្ថែម ២១ ចំណងជើង
- បានផលិតសម្ភារឧបទេស ១១ មុខ
- បានបោះពុម្ពសៀវភៅសិក្សាគោល សៀវភៅហ្វឹកហាត់ និងសៀវភៅអំណានបន្ថែម ២ ១៩៩ ៣០០ ច្បាប់
- បានដឹកជញ្ជូនសៀវភៅសិក្សាគោល ៥ ១៩២ ៦៥០ ច្បាប់ ជូនសាលារៀនទូទាំងប្រទេស
- បានលក់សៀវភៅសិក្សា សម្ភារឧបទេស និងសម្ភារៈការិយាល័យជូនអតិថិជនទូទៅសរុបចំណូល ២ ៨៤៤ ៣៥៩ ៣៣១ រៀល ។

**បទពិសោធ**

- មានវិន័យការងារម៉ឺងម៉ាត់
- មានផែនការការងារច្បាស់លាស់។

## ៤- ការងារពិនិត្យតាមដាន និងវាយតម្លៃ

### ៤.១ ការងារធានាគុណភាពអប់រំ

- បានធ្វើតេស្តវាយតម្លៃថ្នាក់ជាតិថ្នាក់ទី៦ បញ្ចូល និងសម្អាតទិន្នន័យលើមុខវិជ្ជា ភាសាខ្មែរ និងគណិតវិទ្យានៅសាលាបឋមសិក្សាសំណាក ២១០ មានសិស្ស ៦០១៩ នាក់ ស្រី ៥៤,៨២ ភាគរយ
- បានចុះពិនិត្យតាមដានការបំពេញការងារធានាគុណភាពអប់រំនៅតាមការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក និងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ២២
- បានធ្វើអធិការកិច្ចជួយគ្រូបង្រៀននៅសាលារៀនចំណេះទូទៅ ៨៨ និងគ្រូបង្រៀន ១៧៦ នាក់ ស្រី ៥២,២៧ ភាគរយ
- បានចុះពិនិត្យតាមដាននិងវាយតម្លៃគុណភាពអប់រំតាមសាលារៀនចំណេះទូទៅ ១២ខេត្ត មាន ១០៨ សាលា
- បានព្រាងក្របខណ្ឌធានាគុណភាពអប់រំ នៅមត្តេយ្យសិក្សានិងអប់រំចំណេះទូទៅ
- បានបើកសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងឧបករណ៍អធិការកិច្ចតាមកាលកំណត់ និងតាមប្រធានបទ មានអ្នកចូលរួម ១២៩ នាក់ ស្រី ៣២,៥៥ ភាគរយ
- បានបើកវគ្គបំប៉នការអនុវត្តសាកល្បងឧបករណ៍ស្វ័យវាយតម្លៃសាលារៀនមធ្យមសិក្សាចំណេះទូទៅ អ្នកចូលរួម ៣៤៤ នាក់ ស្រី ១៣,៦៦ ភាគរយ
- បានទៅទស្សនៈកិច្ចដកបទពិសោធស្តីពីការងារអធិការកិច្ចនៅប្រទេសស៊ុយអែត។

#### បញ្ហាប្រឈម

- មន្ត្រីពុំទាន់ទទួលបានការបណ្តុះបណ្តាលឱ្យសមស្របតាមបន្ទុកការងារ
- បរិមាណមន្ត្រីជំនាញ និងអធិការនៅពុំទាន់គ្រប់គ្រាន់។

#### បទពិសោធ

- មានកិច្ចសហការល្អជាមួយនាយកដ្ឋានពាក់ព័ន្ធលើការរៀបចំតេស្តវាយតម្លៃថ្នាក់ជាតិ
- មានសហប្រតិបត្តិការល្អជាមួយអធិការដ្ឋានអប់រំប្រទេសស៊ុយអែត ក្នុងការរៀបចំទម្រង់អធិការកិច្ច សម្រាប់ការពង្រឹងប្រព័ន្ធធានាគុណភាពអប់រំនៅមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅ។

### ៤.២ ការងារអធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុ

- បានធ្វើអធិការកិច្ច និងពិនិត្យឡើងវិញលើការងារគ្រប់គ្រងរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋនៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ១៨ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ៦០ និងគ្រឹះស្ថានសិក្សា ៣០១ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ៥ និងសាលាគរុកោសល្យ និងវិក្រឹតការ ៤
- បានបើកវគ្គបំប៉នស្តីពីនីតិវិធីស្រាវជ្រាវ និងដោះស្រាយទំនាស់ និងផ្សព្វផ្សាយរបាយការណ៍អធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុនៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្តាល និងព្រះវិហារ អ្នកចូលរួម ១២៦ នាក់ ស្រី ១៣,៥ ភាគរយ
- បានស្រាវជ្រាវបាតុភាពមិនប្រក្រតី ១៥ ករណី។

### បញ្ហាប្រឈម

- កង្វះស្តង់ដារអធិការកិច្ចថ្នាក់ជាតិ
- បណ្តឹងតវ៉ាពាក់ព័ន្ធវិស័យអប់រំភាគច្រើនមិនបានដោះស្រាយតាមនីតិវិធី។

### បទពិសោធ

- មានលិខិតបទដ្ឋានរបស់រាជរដ្ឋាភិបាល ក្រសួងពាក់ព័ន្ធ និងក្រសួងអប់រំ យុវជន និងកីឡាជាវិធាន
- បានធ្វើបច្ចុប្បន្នកម្មនីតិវិធីអធិការកិច្ច
- មាននីតិវិធី កម្មវិធីអធិការកិច្ច និងបទបញ្ជាផ្ទៃក្នុងសម្រាប់មន្ត្រីអនុវត្ត។

## ៤.៣ ការងារសវនកម្មផ្ទៃក្នុង

- បានបើកវគ្គបំប៉នផ្ទៃក្នុងរយៈពេល ៥ថ្ងៃ និងប្រតិបត្តិផ្ទាល់នីតិវិធីសវនកម្មថវិកាកម្មវិធី
- បានព្រាងសៀវភៅណែនាំស្តីពីនីតិវិធីសវនកម្មថវិកាកម្មវិធី
- បានស្រង់ព័ត៌មានស្តីពីការគ្រប់គ្រង និងប្រើប្រាស់ថវិកាកម្មវិធីនៅថ្នាក់ជាតិ ៨សវនដ្ឋាន សម្រាប់ធ្វើកម្មវិធីសវនកម្ម
- បានធ្វើកម្មសិក្សាសវនកម្មលើការគ្រប់គ្រង និងប្រើប្រាស់ថវិកាកម្មវិធីនៅថ្នាក់ក្រោមជាតិ ៦៦៣ សវនដ្ឋាន។

### បញ្ហាប្រឈម

- សមត្ថភាពមន្ត្រីសវនកម្មពុំទាន់ឆ្លើយតបទៅនឹងនីតិវិធីសវនកម្មថវិកាកម្មវិធី
- ការងារសវនកម្មផ្ទៃក្នុងមិនទាន់បានផ្សព្វផ្សាយឱ្យបានគ្រប់សវនដ្ឋាន។

### បទពិសោធ

- មានការគាំទ្រនិងយកចិត្តទុកដាក់ពីអង្គភាពពាក់ព័ន្ធនិងដៃគូអភិវឌ្ឍ
- មាននីតិវិធីសវនកម្មថវិកាកម្មវិធី និងកម្មវិធីសម្រាប់អនុវត្ត
- មានក្រមសីលធម៌វិជ្ជាជីវៈសវនកម្មផ្ទៃក្នុង។

# សេចក្តីសន្និដ្ឋាន

សមិទ្ធផលខាងលើនេះ បានមកដោយសារការអនុវត្តប្រកបដោយជោគជ័យនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល តាមរយៈផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដោយមានការចូលរួមពីមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ ក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** សំដៅឆ្ពោះទៅមុខប្រកបដោយក្តីសង្ឃឹម និងជំនឿទុកចិត្តយ៉ាងមុតមាំនៅលើមាគ៌ានៃកំណែទម្រង់ និងការអភិវឌ្ឍ។

# ទិសដៅការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០១៣-២០១៤

ផ្អែកលើសមិទ្ធផលកន្លងមក ក្រសួងអប់រំ យុវជន និងកីឡា កំណត់ទិសដៅសម្រាប់អនុវត្តក្នុងឆ្នាំសិក្សា២០១៣-២០១៤ ដើម្បីឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្ត ក្នុងការបន្តអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា តាមរយៈផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ដូចតទៅ៖

## ១. ការងារអប់រំកុមារតូច

- បង្កើនអត្រាចូលរៀនរបស់កុមារអាយុ ៥ឆ្នាំឱ្យបាន ៦២ ភាគរយ កុមារអាយុ ៤ឆ្នាំ ឱ្យបាន ២៨ ភាគរយ និងកុមារអាយុ ៣ឆ្នាំឱ្យបាន ២៣ ភាគរយ
- រៀបចំសាលា ថ្នាក់មត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ កម្មវិធីអប់រំកុមារតូចតាមផ្ទះ/ ខ្នងផ្ទះ ទទួលបានតាមស្តង់ដារ ៥ ភាគរយ
- បន្តពង្រីកកម្មវិធីអប់រំបញ្ចូលគ្នា និងការអប់រំពីរភាសាផ្អែកមត្តេយ្យសិក្សា
- បញ្ចប់ការរៀបចំផែនការសកម្មភាពជាតិសម្រាប់ការគាំពារ និងអភិវឌ្ឍកុមារតូច
- បង្កើនសមត្ថភាពពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផល
- កែលម្អកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ និងអភិវឌ្ឍសមត្ថភាពគ្រូមត្តេយ្យសិក្សា។

## ២. ការងារបឋមសិក្សា

- កាត់បន្ថយអត្រាត្រួតថ្នាក់ និងអត្រាបោះបង់
- បង្កើនចំនួនក្រុង ស្រុក ខណ្ឌ ដែលបានសម្រេចអត្រាបញ្ចប់ការសិក្សាយ៉ាងតិច ៨០ ភាគរយ
- បង្កើនចំនួនសាលារៀនគ្រប់កម្រិតថ្នាក់ដែលមានអត្រាត្រួតថ្នាក់ក្រោម ១០ ភាគរយ
- បង្កើនចំនួនសាលាកុមារមេត្រីកម្រិតមធ្យម និងកម្រិតអភិវឌ្ឍន៍
- ជំរុញការអនុវត្តម៉ោងសិក្សាឱ្យបានត្រឹមត្រូវ
- ជំរុញការអនុវត្តកាលវិភាគទន់ភ្លន់តាមស្ថានភាពជាក់ស្តែងរបស់មូលដ្ឋាន។

## ៣. ការងារមធ្យមសិក្សា

- កែទម្រង់ការប្រឡងគ្រប់ប្រភេទ
- បង្កើតអនុវិទ្យាល័យ និងវិទ្យាល័យនៅឃុំ ស្រុកតាមកំណើនប្រជាជន និងស្ថានភាពជាក់ស្តែង
- ពង្រឹងវិធានការកាត់បន្ថយសិស្សបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ
- រៀបចំគោលនយោបាយអាហារូបករណ៍ ការឧបត្ថម្ភធន និងឥណទានសម្រាប់អ្នកសិក្សា
- ជំរុញការអនុវត្តម៉ោងសិក្សាឱ្យបានត្រឹមត្រូវ
- ពង្រឹងដំណើរការប្រតិបត្តិវិទ្យាល័យធនធាន
- ជំរុញការអនុវត្តកម្មវិធីសាលាកុមារមេត្រីនៅកម្រិតមធ្យមសិក្សាបឋមភូមិ។

## ៤. ការងារតម្រង់ទិសវិជ្ជាជីវៈ

- ពង្រឹង និងពង្រីកការអនុវត្តកម្មវិធីអប់រំបច្ចេកទេស តម្រង់ទិសវិជ្ជាជីវៈ បំណិនជីវិត និងកម្មវិធីពិគ្រោះយោបល់អាជីព នៅមធ្យមសិក្សាចំណេះទូទៅ
- រៀបចំផែនការគោលសម្រាប់អភិវឌ្ឍការអប់រំបច្ចេកទេស នៅសាលាមធ្យមសិក្សាចំណេះទូទៅ
- រៀបចំផែនការសកម្មភាពដើម្បីអនុវត្តគោលនយោបាយស្តីពីការអប់រំបច្ចេកទេស
- រៀបចំកម្មវិធីស្ពានចម្លង សម្រាប់សិស្សបោះបង់ការសិក្សា
- រៀបចំស្តង់ដារវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស
- បន្តសហការជាមួយអង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ ។

## ៥. ការងារអប់រំក្រៅប្រព័ន្ធ

- បង្កើនអត្រាអក្ខរកម្មវិជ្ជាជីវៈ ០,៧ ភាគរយ (អាយុ ១៥- ៤៥ឆ្នាំ)
- ពង្រឹងសកម្មភាពមជ្ឈមណ្ឌលសិក្សាសហគមន៍ បណ្ណាល័យ និងមណ្ឌលអានដែលមានស្រាប់
- បង្កើតបណ្ណាល័យ ៤ និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ២៤
- អនុវត្តកម្មវិធីសមមូលបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ
- ធ្វើបច្ចុប្បន្នកម្ម និងពង្រីកការអនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ។

## ៦. ការងារឧត្តមសិក្សា

- សិក្សាលទ្ធភាពស្តីពីការពង្រីកកម្មវិធីផ្នែកវិទ្យាសាស្រ្ត បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យា
- សិក្សា និងវិភាគស្ថានភាពនិស្សិតក្រោយការបញ្ចប់ការសិក្សា
- កែសម្រួលលិខិតបទដ្ឋានគតិយុត្តស្តីពីការទទួលស្គាល់/ការបង្កើតគ្រឹះស្ថានឧត្តមសិក្សា
- កសាងអនុក្រឹត្យស្តីពីការផ្តល់ស្វ័យភាពដល់គ្រឹះស្ថានឧត្តមសិក្សា
- បង្កើតមហាវិទ្យាល័យអប់រំ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- សិក្សា និងវិភាគស្ថានភាពតម្រូវការ និងការផ្គត់ផ្គង់ទីផ្សារពលកម្ម
- ពង្រឹងបទដ្ឋានធានាគុណភាពអប់រំផ្ទៃក្នុង និងគោលការណ៍ណែនាំគ្រឹះស្ថានឧត្តមសិក្សា
- ពង្រឹងក្របខណ្ឌច្បាប់ និងបទបញ្ញត្តិ ដើម្បីគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា។

## ៧. ការងារស្រាវជ្រាវវិទ្យាសាស្រ្ត

- រៀបចំគោលការណ៍លម្អិតស្តីពីដំណើរការនៃការបណ្តុះបណ្តាលថ្នាក់បណ្ឌិត
- កែសម្រួលគោលការណ៍ស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់
- ពង្រឹងការអនុវត្តប្រកាសស្តីពីលក្ខខណ្ឌនិងលក្ខណវិនិច្ឆ័យលម្អិតនៃការបណ្តុះបណ្តាលថ្នាក់បណ្ឌិត
- ជំរុញគ្រឹះស្ថានបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ធ្វើការស្រាវជ្រាវឲ្យបាន ៥ភាគរយ។

## ៨. ការងារយុវជន

- បង្កើតយន្តការការងារកាយរឹទ្ធិ
- ជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- ពង្រីកវេទិកាយុវជនស្តីពីធុរកិច្ចជាមួយផ្នែកឯកជន
- បង្កើនការផ្សព្វផ្សាយនាទីយុវជនឱ្យបានទូលំទូលាយ
- បង្កើតកម្មវិធីសហគ្រិនភាពនៅតាមគ្រឹះស្ថានមធ្យមសិក្សា
- ពង្រឹងសកម្មភាពក្រុមប្រឹក្សាយុវជន និងក្រុមប្រឹក្សាកុមារឱ្យដំណើរការពេញលេញ។

## ៩. ការងារគ្រប់គ្រងមជ្ឈមណ្ឌលយុវជន

- បើកវគ្គបណ្តុះបណ្តាលយុវជនស្ម័គ្រចិត្ត ៥០ ស្រុក
- បើកវគ្គបណ្តុះបណ្តាលជំនាញខ្លីៗនៅមជ្ឈមណ្ឌលយុវជន ១៦
- សិក្សាស្រាវជ្រាវនិងវាយតម្លៃពីតម្រូវការការងាររបស់យុវជន ១៦ រាជធានី ខេត្ត
- បន្តសហការជាមួយដៃគូអភិវឌ្ឍលើការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ជំនាញទន់ សហគ្រិនភាព និងព័ត៌មានទីផ្សារការងារ
- រៀបចំវេទិកាជាតិស្តីពីការស្ម័គ្រចិត្តនៅកម្ពុជា និងទិវាអន្តរជាតិអ្នកស្ម័គ្រចិត្ត ៥ធ្នូ។

## ១០. ការងារអប់រំកាយ និងកីឡាសិស្ស-និស្សិត

- អនុវត្តកម្មវិធីសិក្សាអប់រំកាយ និងកីឡាឱ្យបានពេញលេញ
- រៀបចំការប្រកួតកីឡាជ្រើសរើសជើងឯកសិស្ស និស្សិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បំប៉នសមត្ថភាពគ្រូអប់រំកាយ និងកីឡានៅគ្រឹះស្ថានបឋមសិក្សា និងគ្រឹះស្ថានមធ្យមសិក្សា
- កសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធទីលានកីឡា និងបំពាក់សម្ភាររូបវន្តតាមគ្រឹះស្ថានសិក្សា
- អភិវឌ្ឍសមាគមកីឡានៅតាមគ្រឹះស្ថានសិក្សា
- ពង្រឹងរចនាសម្ព័ន្ធសហព័ន្ធកីឡាសិស្ស និស្សិត។

## ១១. ការងារអប់រំកាយ និងកីឡា

- ប្រកួតកីឡាមហាជនជ្រើសរើសជើងឯកថ្នាក់ភូមិភាគ និងថ្នាក់ជាតិ
- ធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធកីឡាថ្នាក់ជាតិ
- លើកកម្ពស់សមត្ថភាពមន្ត្រីជំនាញកីឡា
- លើកកម្ពស់សមត្ថភាពមន្ត្រីទទួលបន្ទុកកីឡាលើការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន
- បន្តស្រាវជ្រាវ ចងក្រងឯកសារកីឡាប្រពៃណី និងកីឡាទំនើប
- ធ្វើវិមជ្ឈការការងារបច្ចេកទេសក្នុងការរៀបចំការប្រកួតដល់សហព័ន្ធកីឡាជាតិ
- ពង្រឹងការគ្រប់គ្រងសហព័ន្ធកីឡាជាតិ។

## ១២. ការងារមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា

- លើកកម្ពស់សិទ្ធិផលកីឡាក្នុងការចូលរួមប្រកួតកីឡាអន្តរជាតិនានា តាមរយៈការប្រមូលផ្តុំកីឡាករ និងគ្រូបង្វឹក

- ពង្រឹងសមត្ថភាពគ្រូបង្វឹក កីឡាករ កីឡាការិនី និងមន្ត្រីកីឡា ស្តីពីផែនការហាត់ហ្វឹកហ្វឺន ក្រមសីលធម៌ និងការប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា
- ពង្រីកការយល់ដឹងដល់មន្ត្រីកីឡានិងសាធារណជន តាមរយៈទស្សនាវដ្តីកីឡា
- ធ្វើទំនើបកម្មមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា
- លើកកម្ពស់សិទ្ធិផលកីឡាក្នុងការប្រកួតកីឡាអាស៊ីលើកទី១៧ នៅសាធារណរដ្ឋកូរ៉េ ។

## ១៣. ការងារវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា

- បន្តបណ្តុះបណ្តាលគរុសិស្សជំនាន់ទី២២ ជំនាន់ទី២៣ និងធ្វើការប្រឡងបញ្ចប់ការសិក្សាគរុសិស្ស ជំនាន់ទី២២ និងប្រឡងជ្រើសរើសជំនាន់ទី២៤
- រៀបចំផែនការបណ្តុះបណ្តាលគ្រូអប់រំកាយនិងកីឡាកម្រិតឧត្តម
- ស្រាវជ្រាវ និងចងក្រងឯកសារវិទ្យាសាស្ត្រកីឡា សម្រាប់បណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡា
- លើកកម្ពស់សមត្ថភាពគ្រូអប់រំកាយ និងកីឡាតាមអនុវិទ្យាល័យ និងវិទ្យាល័យ។

## ១៤. ការងារផែនការ

- ជំរុញការប្រមូលស្ថិតិស្តីពីលទ្ធផលសិក្សារបស់សិស្ស
- ជំរុញការប្រើប្រាស់ទិន្នន័យស្ថិតិអប់រំតាមប្រព័ន្ធព័ត៌មានវិទ្យា និងទូរគមនាគមន៍
- ធ្វើបច្ចុប្បន្នកម្មផែនទីទីតាំងសាលារៀន
- ជំរុញការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់ក្រោមជាតិ
- ពង្រឹងការគ្រប់គ្រងព័ត៌មានស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការនៅថ្នាក់ក្រោមជាតិ
- ពង្រឹងការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំតាមអង្គភាព
- លើកកម្ពស់សមត្ថភាពមន្ត្រីជំនាញ និងពង្រឹងប្រព័ន្ធការងារផែនការ ស្ថិតិ។

## ១៥. ការងារបុគ្គលិក

- អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ការងារគ្រប់គ្រងបុគ្គលិកក្នុងវិស័យអប់រំ យុវជន និងកីឡា
- ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តមសម្រាប់បម្រើការតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ
- ប្រឡងប្រជែងដើម្បីផ្លាស់ប្តូរប្រភេទក្របខ័ណ្ឌបុគ្គលិកអប់រំ
- ពង្រឹងសមត្ថភាពមន្ត្រីលើការប្រើប្រាស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស
- អភិវឌ្ឍផែនការសកម្មភាពដើម្បីអនុវត្តគោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ។

## ១៦. ការងារនីតិកម្ម

- អភិវឌ្ឍ និងពិនិត្យផ្តល់យោបល់លើគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តក្នុងច្បាប់ស្តីពីការអប់រំ ១៣ និងគាំទ្រច្បាប់ស្តីពីការអប់រំ ៥ និងពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្តវិស័យអប់រំ
- អភិវឌ្ឍយន្តការនានា និងពង្រឹងការផ្តល់សេវាសាធារណៈវិស័យអប់រំ ផ្អែកលើគោលការណ៍អភិបាលកិច្ចល្អ
- អនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ

- អភិវឌ្ឍយន្តការគតិយុត្តនានា និងពង្រឹងការពិនិត្យតាមដានវិវាទបុគ្គលិកអប់រំ
- ពង្រឹងការអនុវត្តយន្តការច្រកចេញចូលតែមួយឱ្យមានប្រសិទ្ធភាព
- គ្រប់គ្រងទិន្នន័យលិខិតបទដ្ឋានគតិយុត្តតាមប្រព័ន្ធព័ត៌មានវិទ្យា។

## ១៧. ការងារហិរញ្ញវត្ថុ

- បន្តអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ត្រៀមបង្កើតអង្គភាពថវិកា ដើម្បីអនុវត្តថវិកាកម្មវិធីពេញលេញនៅឆ្នាំ ២០១៥
- រៀបចំផែនការចំណាយរយៈពេលមធ្យមឆ្នាំ ២០១៥- ២០១៧ និងគម្រោងថវិកាឆ្នាំ ២០១៥
- កែសម្រួលអនុក្រឹត្យ និងប្រកាសអន្តរក្រសួង ដែលពាក់ព័ន្ធដល់ការអនុវត្តថវិកា
- ពង្រឹង និងពង្រីកការប្រើប្រាស់ប្រព័ន្ធធនាគារ និងប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ។

## ១៨. ការងារអភិវឌ្ឍកម្មវិធីសិក្សា

- ធ្វើបច្ចុប្បន្នកម្មគោលនយោបាយកម្មវិធីសិក្សា កម្មវិធិសិក្សាគោល និងកម្មវិធីសិក្សាលម្អិត
- ផ្គត់ផ្គង់សៀវភៅសិក្សាគោលគ្រប់កម្រិតថ្នាក់ ៤ ៣៤៦ ០០០ ក្បាល
- ផលិតឯកសារបញ្ជ្រាបខ្លឹមសារបន្សាំការប្រែប្រួលអាកាសធាតុក្នុងកម្មវិធីសិក្សាថ្នាក់ទី៧ ដល់ទី៩
- បញ្ចូលខ្លឹមសារប្រឆាំងអំពើពុករលួយក្នុងកម្មវិធីសិក្សាថ្នាក់ទី ១០ ដល់ ទី១២។

## ១៩. ការងារបណ្តុះបណ្តាល និងវិក្រឹតការ

- លើកទឹកចិត្តអ្នកមានសមត្ថភាពឱ្យចូលបម្រើវិជ្ជាជីវៈគ្រូបង្រៀន
- លើកកម្ពស់សមត្ថភាពគ្រូបឋមសិក្សា និងមត្តេយ្យសិក្សាដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឱ្យទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋាន
- ពង្រឹងសមត្ថភាពគ្រប់គ្រងជូននាយក នាយករង នាយិកា នាយិការងសាលាគរុកោសល្យ សាលាមត្តេយ្យសិក្សា សាលាបឋមសិក្សា និងសាលាមធ្យមសិក្សាចំណេះទូទៅ
- ពង្រឹងសមត្ថភាពគ្រូឧទ្ទេសលើផ្នែកវិធីសាស្រ្តបង្រៀន
- លើកកម្ពស់សមត្ថភាពគ្រូមធ្យមសិក្សាបឋមភូមិលើផ្នែកវិទ្យាសាស្រ្ត និងគណិតវិទ្យា
- លើកកម្ពស់សមត្ថភាពគ្រូបង្រៀនបឋមសិក្សា អំពីការបង្រៀនភាសាអង់គ្លេស
- អភិវឌ្ឍផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀន។

## ២០. ការងារសុខភាពសិក្សា

- បន្តកែសម្រួលប្រកាសអន្តរក្រសួងស្តីពីការពិនិត្យសុខភាពនិងកាយសម្បទាដល់បុគ្គលិកអប់រំ និងអ្នកសិក្សា និងសារាចរណែនាំស្តីពីរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចសុខភាពសិក្សានៅថ្នាក់ក្រោមជាតិ
- លើកកម្ពស់សុខភាព អនាម័យ អាហារូបត្ថម្ភ សុវត្ថិភាពនិងសុខុមាលភាពចំណីអាហារ វិធីសាស្រ្តសង្គ្រោះបឋម សុខភាពផ្លូវភេទ សុខភាពបន្តពូជ និងសុខភាពភ្នែក
- ផ្តល់សម្ភារបរិក្ខារផ្នែកអនាម័យ ព្រមទាំងផ្តល់ប្រអប់សង្គ្រោះបឋមតាមសាលារៀន
- អប់រំបង្ការជំងឺឆ្លងនានាដូចជាជំងឺគ្រុនចាញ់ ជំងឺគ្រុនឈាម ដង្កូវព្រូន ។ល។

## ២១. ការងាររដ្ឋបាល

- ពង្រឹងការរៀបចំរបាយការណ៍បូកសរុបការងារអប់រំ យុវជន និងកីឡា
- ជំរុញការផ្តល់គ្រឿងឥស្សរិយយសការងារជូនបុគ្គលិកអប់រំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- លើកកម្ពស់សមត្ថភាពការងារគ្រប់គ្រងរដ្ឋបាល និងបណ្ណសារ។

## ២២. ការងារទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍

- ពង្រឹងការគ្រប់គ្រងនិស្សិតអាហារូបករណ៍ក្នុងនិងក្រៅប្រទេសតាមប្រព័ន្ធព័ត៌មានវិទ្យា
- ជំរុញការផ្សព្វផ្សាយកម្មវិធីអាហារូបករណ៍ទៅសិក្សានៅបរទេសចំពោះតំបន់ដាច់ស្រយាលជួបការលំបាកឱ្យបានទូលំទូលាយ
- ពង្រឹងកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ លើការរៀននិងបង្រៀនភាសាបារាំង។

## ២៣. ការងារព័ត៌មាន និងកិច្ចការអាស៊ាន

- បន្តប្រមូលព័ត៌មាន និងផ្សព្វផ្សាយសមិទ្ធផលអប់រំ យុវជន និងកីឡា
- បង្កើនការចុះឈ្មោះចូលរៀនរបស់កុមារអាយុ ៦ឆ្នាំ តាមគោលដៅ នៃស្រុក ខេត្តជួបការលំបាកតាមរយៈយុទ្ធនាការអប់រំ
- បន្តរៀបចំគោលនយោបាយស្តីពីការអប់រំពីចម្ងាយ
- លើកកម្ពស់សមត្ថភាពបុគ្គលិកអប់រំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិស្តីពីការប្រើប្រាស់កុំព្យូទ័រកម្រិតមូលដ្ឋាន និងកម្រិតមធ្យម
- ពង្រឹងមន្ត្រីបង្គោលទទួលបន្ទុកបញ្ចូលទិន្នន័យទៅក្នុងគេហទំព័ររបស់ក្រសួង
- លើកកម្ពស់កិច្ចសហប្រតិបត្តិការល្អលើវិស័យអប់រំ យុវជន និងកីឡាជាមួយប្រទេសដៃគូក្នុងតំបន់និងពិភពលោក។

## ២៤. ការងារគ្រប់គ្រងសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ

- ពង្រឹងការលើកគម្រោងតម្រូវការ និងការផ្គត់ផ្គង់សម្ភារបរិក្ខារ
- លើកកម្ពស់សមត្ថភាពមន្ត្រីទទួលបន្ទុកគ្រប់គ្រងសម្ភារៈនិងទ្រព្យសម្បត្តិរដ្ឋ
- ជំរុញការធ្វើបញ្ជីសារពើភ័ណ្ឌ របាយការណ៍សន្និធិ និងតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើងថយចុះ
- ជំរុញការប្រមូលចំណូល ការធ្វើប័ណ្ណកាន់កាប់អចលនទ្រព្យ ការធ្វើបញ្ជីជាតិដី បញ្ជីអចលនទ្រព្យនិងការដោះស្រាយវិវាទ
- កសាងនិងកែសម្រួលឯកសារគតិយុត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

## ២៥. ការងារសំណង់សិក្សា

- ជំរុញការសាងសង់ ជួសជុលហេដ្ឋារចនាសម្ព័ន្ធអប់រំ
- ចុះសិក្សាទីតាំងនិងសាងសង់អគារ ក្នុងគម្រោងនានា ៨៣៩ ទីតាំង
- សិក្សានិងរៀបចំគម្រោងជួសជុលសាលារៀនដែលរងផលប៉ះពាល់ដោយគ្រោះធម្មជាតិ

- កែតម្រូវគ្រឿងបង្គុំសំណង់ដើម្បីបង្ការគ្រោះធម្មជាតិ
- ពង្រឹងការថែទាំអគារសិក្សានិងសម្ភារបរិក្ខារ។

## ២៦. ការងារបោះពុម្ព និងចែកផ្សាយ

- អភិវឌ្ឍសៀវភៅសិក្សាគោល ហ្វឹកហាត់ អំណានបន្ថែម និងសម្ភារឧបទេសផ្សេងៗ
- បោះពុម្ពសៀវភៅសិក្សាគោល ហ្វឹកហាត់ និងអំណានបន្ថែម
- ដឹកជញ្ជូនសៀវភៅសិក្សាគោលជូនសាលារៀន តាមផែនការក្រសួងអប់រំ យុវជន និងកីឡា
- ពង្រីកការលក់សៀវភៅសិក្សា សម្ភារឧបទេស និងសម្ភារការិយាល័យជូនអតិថិជនទូទៅ
- ដាក់ឈ្មោះរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌលើក្របសៀវភៅសិក្សាគោលផ្នែកខាងមុខ។

## ២៧. ការងារធានាគុណភាពអប់រំ

- ពង្រឹងការបំពេញការងារធានាគុណភាពអប់រំតាមរាជធានី ខេត្ត
- ធានាគុណភាពអប់រំតាមរយៈការធ្វើតេស្តវង្វាយតម្លៃថ្នាក់ជាតិថ្នាក់ទី៨ មុខវិជ្ជាភាសាខ្មែរ រូបវិទ្យា និងគណិតវិទ្យានៅសាលារៀនសំណាកគំរូ ២០០
- បន្តរៀបចំគោលការណ៍ យន្តការសម្រាប់វាស់ស្ទង់សមត្ថភាពកម្រិតសមមូល
- បន្តកសាងក្របខណ្ឌ និងឧបករណ៍ធានាគុណភាពអប់រំ
- បញ្ចប់ការកែលម្អក្របខណ្ឌស្វ័យវាយតម្លៃសាលារៀនមធ្យមសិក្សាចំណេះទូទៅ។

## ២៨. ការងារអធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុ

- ធ្វើអធិការកិច្ច និងពិនិត្យឡើងវិញលើការងារគ្រប់គ្រងរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ៤៥០ អង្គភាព
- បង្កើនការយល់ដឹងស្តីពីនីតិវិធីស្រាវជ្រាវទំនាស់
- ចែករំលែកបទពិសោធស្តីពីអធិការកិច្ចរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ
- ចុះស្រាវជ្រាវពាក្យបណ្តឹង ឬបាតុភាពមិនប្រក្រតីពាក់ព័ន្ធវិស័យអប់រំ
- កំណត់ស្តង់ដារអធិការកិច្ចដោយប្រើសៀវភៅណែនាំនីតិវិធីអធិការកិច្ច។

## ២៩. ការងារសវនកម្មផ្ទៃក្នុង

- លើកកម្ពស់សមត្ថភាពមន្ត្រីសវនកម្ម
- គាំទ្រកិច្ចដំណើរការសវនកម្ម តាមរយៈការផ្សព្វផ្សាយនីតិវិធីសវនកម្មថវិកាកម្មវិធី
- ពង្រឹងការគ្រប់គ្រង និងការប្រើប្រាស់ថវិកាកម្មវិធីតាមសវនដ្ឋាន។